ខ្មែរប៉ុស្ដិ៍
ផ្នែកខាងកើត
Bye Bye 2009
THE KHMER POST
ISSUE 50 24th December 2009 _ 09th January 2010

សមាគមខ្មែរមានអាយុ៣០ឆ្នាំ

លោក រឿម ផ្សុង បង្ហាញពីសមាជិកភាពសមាគមខ្មែរ

•••សមាគមខ្មែរបានប្រារព្ធខួបទី ៣០ឆ្នាំរបស់ខ្លួន នៅមន្ទីរសិល្បៈខ្មែរ កាលពីចុងសប្ដាហ៍មុន ប្រកបដោយមោទនភាពពិសេស ។ បូណា និង មុបវាំញស្ដាញ ម្ចាស់អាគារមន្ទីរសិល្បៈ ប្រកបដោយវត្ថុសិល្បៈខ្មែរ ជាច្រើនសន្ធឹកសន្ធាប់គ្រប់កាលសម័យ បានបើកទទួលភ្ញៀវរបស់សមាគមខ្មែរ ហើយចូលរួមក្នុងសកម្មភាពលើកកំពស់ ប្បធម៌ខ្មែរ ដែលជំនឿនេះបានចុះថយយ៉ាងច្រើន ចាប់តាំងពីរបបកុម្មុយនីស្ដ ចូលមកកាន់កាប់វាសនាកម្ពុជា ពេលណាមក ។ សមាគមខ្មែរ តាមរយៈការដឹកនាំបន្ដ បន្ទាប់តាំងពី ៣០ឆ្នាំមក បានយកវប្បធម៌ដ៏រុងរឿងរបស់ខ្មែរ ជាមុខព្រួញដ៏សំខាន់បំផុត សម្រាប់ឱ្យមានការ ទទួលស្គាល់សហគមន៍ខ្មែរ នៅហ៊ីឡារំដែលហ្នឹងនេះ ហើយនៅបីឆ្នាំចុងក្រោយនេះ មោទនភាពនៃសហគមន៍មួយដែលធ្លាប់រុងរឿងបានងើបឡើងវិញ ជាមួយនឹងកំណើតនៃមន្ទីរសិល្បៈខ្មែរ - វិទ្យុខ្មែរ និងការសែតខ្មែរ ឥឡូវភោជនីយដ្ឋានខ្មែរ អតីតយុទ្ធជនខ្មែរ វត្តខ្មែរ តំណាងខ្មែរនៅសាលាក្រុង ។ល។ តទៅទំព័រទី ៣

វិបត្តិនៅវិទ្យាល័យហ្វីឡាខាងត្បូង (ត)

ដោយ : ពិន សំខុន

បាតុកម្មសិស្សអាស៊ីនៅសួនឌ្យូស្ដីក

•••សិស្សនៅវិទ្យាល័យ ហ្វីឡាខាងត្បូង ជាង ១០នាក់ ដែលដឹកនាំកូដកម្មមិនចូលរៀនតាំងពីរអាទិត្យហើយនោះ បានប្រកាសបញ្ចប់កូដកម្មរបស់ក្រុមសិស្សអាស៊ី បន្ទាប់ពីជួបពិភាក្សាជាមួយនាយកក្រសួងអប់រំ អាកលីន អាក់ម៉ាន់ (Arlene Ackerman) និងអ្នកគ្រប់គ្រងក្រសួងអប់រំឯទៀតៗ កាលពីថ្ងៃអង្គារ ទី១៦ ធ្នូ ២០០៩ រួចមក ។ នាយកសាលា និងនាយកក្រសួង បានសន្យាធានាសុវត្ថិភាពជូនដល់សិស្សជាង ៥០នាក់ ដែលបាននាំគ្នាធ្វើកូដកម្ម ដោយសនិយាយថា " យើងនឹកដល់អ្នក... យើងចង់ឱ្យអ្នកត្រឡប់មកសាលាវិញ... យើងនឹងជួយគ្រប់យ៉ាងទាំងអស់... " ។

កូដកម្មនេះ បានកើតឡើងនៅថ្ងៃទី ៣ ខែធ្នូ មុននេះដោយក្រុសសិស្សអាហ្រ្វិកាំង-អាមេរិកាំង ប្រដេញវាយតប់សិស្សអាស៊ី នៅក្នុងបរិវេណ និងក្រៅវិទ្យាល័យហ្វីឡាខាងត្បូង អស់តយៈពេលមួយថ្ងៃ បណ្ដាលឱ្យមានរបួសប្រមាណ ២០នាក់ ហើយដឹកមន្ទីរទេព្យ ៧នាក់ ។ ក្រុមសិស្សអាស៊ីបានប្រជុំគ្នា ប្រកាសផ្ដើមកូដកម្មមិនចូលរៀន រហូតដល់ក្រសួង និងវិទ្យាល័យផ្ដល់កិច្ចការពារគ្រប់គ្រាន់ដល់ពួកគេ ដោយថ្លែងថា " វិទ្យាល័យហ្វីឡាខាងត្បូង ពុំផ្ដល់សុវត្ថិភាពឱ្យពួកយើងទេ - យើងត្រូវគេគំគួន ដោយសារតែយើងជាពួកអាស៊ី អន្ដោប្រវែនន័-រៀងរាល់ថ្ងៃយើងរងូវគេជេ និងធ្វើបាប ។ យើងឈឺចាប់ណាស់ នៅពេលត្រូវសិស្សឯទៀត វាយធ្វើបាបយើង តែយើងឈឺចាប់រឹតតែខ្លាំង នៅពេលបុគ្គលិកវិទ្យាល័យមិនអើពើ មិនទទួលស្គាល់ ឬក៏លាក់បំបាំងការវាយ ដោយប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ស្បែក មកលើយើង ។ យើងសម្រេចធ្វើកូដកម្មប្រឆាំងសាលាយើង ដោយយើងចង់ឱ្យមានការធានាសុវត្ថិភាពយ៉ាងណាដល់ពួកយើង - សិស្សស្ទើរតែទាំងអស់នៅវិទ្យាល័យហ្វីឡាខាងត្បូង មានអាស៊ី, អាហ្រ្វិកឡាទីណូ និងពួកស្បែកស ស្ថិតនៅក្នុងសភាពដូចយើងដូច្នោះដែរ ។ ទាំងអស់គ្នានសាកល្បង

តទៅទំព័រទី ១៥

Yoo's Auto Service and Collision

យូ បំរើសេវារថយន្ត
និងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

អោយជាងម៉ាស៊ីន

Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More

FREE ESTIMATES

យើងនឹងជូសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត
តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

COUPON
$10 OFF TOWARD EMISSION AND STATE INSPECTION

អោយជូសជុលតួរថយន្ត

Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists

ទូរស័ព្ទ SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475
189 W. Duncannon Ave. Phila., PA 19120

777-200ER

ពីញូយ៉កទៅតាយប៉េ
ហោះ ៤ ជើងក្នុងមួយសប្ដាហ៍

ចាប់ផ្ដើមហោះហើរពីថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៥ //
"អេវ៉ា" អាកាសចរមានសេវា ញូយ៉ក-តាយប៉េ នៅថ្ងៃច័ន្ទ ថ្ងៃពុធ-ថ្ងៃព្រហស្បត្ដិ៍
និងថ្ងៃសៅរ៍...ធ្វើឱ្យដំណើរទៅកាន់ទ្វីបអាស៊ីមានភាពប្រសើរគ្មានពេលណាដូច
យន្ដហោះថ្មីធុន ជាមួយនឹងបន្ទប់ធំទូលាយ និងមានបច្ចេកទេសទំនើបចែកជា
ថ្នាក់អ្នកដំណើរទី១ ថ្នាកអ្នក់ដឹកនាំ និងថ្នាក់អ្នកដំណើរមធ្យម មានបន្ទប់
បុគ្គលិកគួរឱ្យចូលចិត្ដ សម្រាប់បង្កើនបរិយាកាសសម្រាកកាយ និងកក់ក្ដៅ
ក្នុងចិត្ដ ធ្វើឱ្យដំណើរលោកអ្នកវិតវែកអាយប្រសើរឡើង ។



EVA AIR
Sharing the World, Flying Together

EVA Wings -- Booking, Buying and Bonuses just a click away at www.evaair.com
Contact us at our local service hotline: 800-695-1188

កូនខ្មែរដំបូងគេក្នុងប្រវត្តិសាស្ត្រជាបេក្ខជនសភាតំណាងរាស្ត្រអាមេរិក

ក្រុងខ្មែរ ឡុងប៊ិច : មាជ សុវណ្ណារ៉ា

•ថ្លែងទៅកាន់មនុស្សម្នាក្នុងពិធីរៃអង្គាសប្រាក់ដើម្បីគាំទ្របេក្ខភាពជាអ្នកតំណាងរាស្ត្រអាមេរិក មាស សែម បានបង្ហើបសំដីរបស់លោកដោយភាពញញឹមថា "គាំទ្រខ្ញុំ គឺគាំទ្រ ខ្មែរទាំងអស់គ្នា ដើម្បីនាំសំឡេងខ្មែរ និងកិត្តិយសជាតិខ្មែរនៅជាវិមានរដ្ឋសភាអាមេរិកក្នុងការស្វែងរកការគាំទ្រ និងការចាប់អារម្មណ៍ដោយមានការយកចិត្តទុកដាក់ពីរដ្ឋាភិបាលអាមេរិក សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងដំណោះស្រាយបញ្ហាផ្សេងៗនៅតាមសហគមន៍ខ្មែរយើងនានាក្នុងទូទាំងសហរដ្ឋអាមេរិក" ។ មាស សែម ថ្លែងបន្តថា "ខ្ញុំរំភើប ហើយមានកម្លាំងចិត្តនៅពេលឃើញបងប្អូនខ្មែរយើងចេះជួយគាំទ្រគ្នា ដូចជារាត្រីនេះ (ថ្ងៃធ្វើពិធី 4 ធ្នូ 2009) ដែលបាននាំគ្នាមកជួយគាំទ្រខ្ញុំទាំងការជួយលើកទឹកចិត្តទាំងការជួយទំនុកបម្រុងផ្នែកថវិកាដល់ការជំរុញឱ្យខ្ញុំជាកូនខ្មែរធ្វើដំណើរឆ្ពោះទៅកាន់វិមានរដ្ឋសភាជាអ្នកតំណាងរាស្ត្រអាមេរិក និងជាតំណាងខ្មែរផងនោះ" ។

មាស សែម គឺជាបេក្ខជនតំណាងរាស្ត្រអាមេរិកប្រចាំរដ្ឋ ម៉ាហ្សាឈូសេត ពីគណបក្សសាធារណៈរដ្ឋក្នុងការត្រៀមខ្លួនឈរឈ្មោះឱ្យពលរដ្ឋអាមេរិកាំងបោះឆ្នោតឱ្យនៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ2010 ។

ក្នុងពិធីជួបជុំដើម្បីរៃអង្គាសថវិកាគាំទ្រដល់បេក្ខជនតំណាងរាស្ត្រអាមេរិករបស់ មាស សែម នាថ្ងៃទី4 ធ្នូ ឆ្នាំ 2009 គេសង្កេតឃើញបងប្អូនខ្មែរជាងមួយរយនាក់ មកពីគ្រប់ទិសទីក្នុងរដ្ឋ California ជួបជុំគ្នាដើម្បីផ្តល់កម្លាំងចិត្តកម្លាំងកាយ រួមទាំងការបរិច្ចាគវិភាគទានដល់បេក្ខជនកូនខ្មែរមួយរូបនេះ ។ ពិធីបានចាប់ផ្តើមពីម៉ោង7យប់ទៅ ដោយមានការគោរពភ្លេងជាតិខ្មែរ និងអាមេរិកព្រះសង្ឃសូត្រជ័យន្តោ ក្រុមរបាំខ្មែររាំពត់ពេនជូនពរពិធីជាដើម ។

នៅក្នុងការថ្លែងសន្ទរកថា បេក្ខជនសភាតំណាងរាស្ត្រអាមេរិក មាស សែម បានថ្លែងថា យើងអាចកសាងបានទូវចំនុកចិត្តរវាងគ្នា និងគ្នាដោយការជឿទុកចិត្តគ្នានោះ ជនជាតិខ្មែរ-អាមេរិកាំងនឹងមិនរស់នៅក្នុងភាពងកោ ឬក្នុងភាពភ័យខ្លាចឡើតទេ ពីព្រោះយើងបានរួបរួមគ្នា ធ្វើជាមួយគ្នាទទួលជោគជ័យជាមួយគ្នា និងការចែករំលែកផលជាមួយគ្នានាពេលអនាគតនូវចក្ខុវិស័យនៃការផ្លាស់ប្តូរគោលគំនិតជាសំខាន់ គឺនៅទីនេះក្រុង Long Beach មាន Cambodia Town ហើយ ដែលនឹងមាន Khmer Town

តទៅទំព័រទី...

បេក្ខជន មាស សែម (រូបថតខ្មែរប៉ុស្តិ៍- ភិន់ថា ឯល)

(តមកពីទំព័រទី ០១)

សមាគមខ្មែរមានអាយុ...

ជាណាលី និស្សិតផ្នែកសារព័ត៌មាននៃសកលវិទ្យាល័យ "ថែមពិល" បានធ្វើសេចក្តីរាយការណ៍ឱ្យ ខ្មែរប៉ុស្តិ៍ ពីខួប ៣០ឆ្នាំរបស់សមាគមខ្មែរដូចតទៅ :

Author : Dannaly Sam

CAGP Recognizes the Past Thirty Years

The Cambodian Association of Greater Philadelphia (CAGP) hosted a celebratory event on late Friday night of December 18th at the Khmer Art Gallery. The event not only celebrated Cambodian culture with dances and performances that captured the Khmer people's voices in light of the past thirty years, but the Association's members were also honored with awards for their service to the Cambodian-American community. The night's performances and speeches ranged in different formats that included traditional Khmer music and dance, a speech given by Dr. Ben Kiernan, a recounting of Anida Yoeu Ali's experience during the Khmer Rouge years, a performance by Linda Son that brought forth the pain of losing a loved one, and entertainment by the AZI Fellas whose main message in their performance was to "strive on."

In a speech given by Rorng Sorn before the awards ceremony, she clearly stated the event's main message with the words, CONTINUED ON PAGE 16

The Khmer Post Directory
East Coast Publication
Regional Editor : Pin Samkhon
Email : pinsamkhon@gmail.com
Writers : Mam Yin, Kim Phean, Dannaly Sam
Advertising
Marketing Manager : Sabane Thach
Phone : 267-253-3947
Email : sabane.thach@gmail.com

VP Auto Center
បំរើសេវារថយន្ត
ធីងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច
■Mechanic Service ■Body Repair ■State Inspection ■Towing Service
យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត
តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

អោយជាងម៉ាស៊ីន
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission Inspection & Repairs
Muffler & More
អោយជួសជុលតួរថយន្ត
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists
601W. Fisher Ave. Phila., PA 19120
Tel : 215-455-9999/215-329-4444/ Fax : 215-455-3757

វ៉ាន់ ឌីការអុន ថា ហ៊ុន សែន មានអំណាចយួនក៏មានឥទ្ធិពល

សម រង្ស៊ី តំណាងរាស្ត្រត្រូវគេដកអភ័យឯកសិទ្ធិ

ភ្នំពេញ, ខ្មែរប៉ុស្ដិ៍ : ចាន់ កុសល

•••អ្នកភាសាវិទូ អ្នកនយោបាយជាតិ និងអន្តរជាតិមួយចំនួនបានបញ្ចេញទស្សនៈថា ប្រទេសកម្ពុជាហាក់ដូចជាស្ថិតនៅក្រោមអំណាចរបស់ ហ៊ុន សែន តែម្នាក់ហើយអាចបង្កព្យុះភ្លៀវិបានតាមអំពើចិត្ត ។ បើកាលណា ហ៊ុន សែន នៅមានអំណាច យួនក៏នៅតែមានឥទ្ធិពលនៅក្នុងស្រុកខ្មែរដែរ ដូចជាចង់ដកអភ័យឯកសិទ្ធិតំណាងរាស្ត្រជាដើម ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី ត្រូវបានរដ្ឋសភាមកពីកូតាគណបក្សប្រជាជនកម្ពុជាសម្រេចជាឯកច្ឆន្ទដកអភ័យឯកសិទ្ធិម្តងទៀតហើយ។ ក្រោយលេសបើកផ្លូវឱ្យតុលាការខេត្តស្វាយរៀង ធ្វើការស៊ើបអង្កេតក្នុងករណីដកបង្គោលព្រំដែនរវាងប្រទេសកម្ពុជា-យួន ។ ការដកអភ័យឯកសិទ្ធិនេះត្រូវបានគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សធ្វើពហិការមិនចូលរួមប្រជុំ និងមានប្រតិកម្មពីអង្គការសង្គមស៊ីវិលមួយចំនួនទៀតផង ។

រដ្ឋសភាដែលស្ថិតនៅក្រោមអធិបតីភាពលោក ហេង សំរិន និងសមាជិក87រូបបានឯកភាពគ្នាដកអភ័យឯកសិទ្ធិរបស់លោក សម រង្ស៊ី តាមការស្នើសុំរបស់តុលាការខេត្តស្វាយរៀងទាំងតក់ក្រហល់ និងមិនបានកោះហៅ លោក សម រង្ស៊ី មកបំភ្លឺបន្តិចសោះ ។ ក្នុងពេលនោះសូម្បីតែអ្នកកាសែតក៏គេមិនអនុញ្ញាតឱ្យចូលទៅយកព័ត៌មានដែរ ។

រដ្ឋសភាបានចេញសេចក្តីប្រកាសព័ត៌មានថា សភាបានពិនិត្យឃើញថា ការដកអភ័យឯកសិទ្ធិពីលោក សម រង្ស៊ី នេះមកពីលោកបានបំផ្លិចបំផ្លាញតម្រុយបង្គោលព្រំដែនកម្ពុជា-យួន កាលពីថ្ងៃទី25 ខែតុលាកន្លងទៅនេះ នៅលើទឹកដីខេត្តស្វាយរៀង និងញុះញង់បទល្មើសឧក្រិដ្ឋមជ្ឈិមមិនបានសម្រេច។

ខណៈពេលដែលសភាប្រជុំដកអភ័យឯកសិទ្ធិលោក សម រង្ស៊ី ជាលើកទី3នេះ តំណាងរាស្ត្រគណៈបក្ស សម រង្ស៊ី ចំនួន23រូបបាននាំគ្នាលើកផែនទីប្រទេសកម្ពុជា និងអំពាវនាវឱ្យប្រទេសជិតខាងគោរពនូវបូរណភាពទឹកដីរបស់កម្ពុជាជាដាច់ខាត ។

លោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សជំទាស់ក៏បានអានសេចក្តីថ្លែងការណ៍ជំទាស់យ៉ាងដាច់អហិង្សាចំពោះការដកអភ័យឯកសិទ្ធិ សម រង្ស៊ី ហើយទង្វើនេះថា រំលោភចំពោះរដ្ឋធម្មនុញ្ញ ។

សេចក្តីថ្លែងការណ៍នោះបានចំអកឱ្យរដ្ឋាភិបាលហ៊ុន សែន ថា វិធានការនេះបានរំលោភទៅលើរដ្ឋធម្មនុញ្ញ និងអនុវត្តយ៉ាងត្រឹមត្រូវចំពោះបទបញ្ជារបស់រដ្ឋាភិបាលយួន ។ ដោយសារតែកាលពីដើមខែវិច្ឆិកា នាយករដ្ឋមន្ត្រី យួន ង្វៀង តាំងយុន បានស្នើឱ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការចំពោះតំណាងរាស្ត្រ សម រង្ស៊ី និងមិនអនុញ្ញាតឱ្យមានបញ្ហាស្រដៀងគ្នាកើតឡើងឡើយ ។

សេចក្តីថ្លែងការណ៍បញ្ជាក់ថា ក្នុងនាមជាអ្នកតំណាងរាស្ត្រលោក សម រង្ស៊ី គ្រាន់តែបង្ហាញការឈឺចាប់គាំទ្រជាមួយនឹងពលរដ្ឋខ្លួន ដែលត្រូវប្រទេសជិតខាងរំលោភបំពានយកនៅខេត្តស្វាយរៀងក៏វាមិនបានដែរ ។ ទង្វើរបស់សភាជាតិបែបនេះវាបង្ហាញយ៉ាងច្បាស់ថា រដ្ឋាភិបាល ហ៊ុន សែន ក៏ដូចជារដ្ឋសភាមិនខ្វល់នឹងព្រះរាជចំណាររបស់សម្តេច នរោត្តម សីហនុ ជាអតីតព្រះមហាក្សត្រ និងកសិករ ដែលកំពុងតែឈឺចាប់ និងការបាត់បង់ដីស្រែចម្ការនោះទេ។ ការដកលោក សម រង្ស៊ី នេះវាមិនខុសប្លែកពីអនុវត្តតាមបទបញ្ជាមេដែលត្រូវអាម៉ាស តាមរយៈយុទ្ធសាស្ត្រវាទទីទឹកដីឡើយ ។

តំណាងរាស្ត្រគណបក្ស សម រង្ស៊ី តវ៉ានៅមុខរដ្ឋសភា

ក្នុងសេចក្តីថ្លែងការណ៍នៅមុខរដ្ឋសភានេះ គណៈបក្ស សម រង្ស៊ី បានស្នើសុំឱ្យគណៈកម្មាធិការព្រំដែនចុះពិនិត្យបង្គោលព្រំដែនឱ្យបានច្បាស់ សុំឱ្យរដ្ឋាភិបាលហ៊ុន សែន គោរពតាមព្រះរាជចំណាររបស់អតីតព្រះមហាក្សត្រនរោត្តម សីហនុ ដែលឆ្លើយតបចំពោះលិខិតរបស់លោក សម រង្ស៊ី នោះ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស 23 តុលា 1991 ។

នៅថ្ងៃដែលដកអភ័យឯកសិទ្ធិសភានោះ លោក សម រង្ស៊ី មិនមានវត្តមាននៅក្នុងប្រទេសឡើយ ប៉ុន្តែបើយោងតាមកាសែត The Phnom Penh Post ដែលបានធ្វើបទសម្ភាសន៍ពីប្រទេសបារាំងបានស្រង់សំដីថា លោកមិនបានដឹងរឿងនេះទេ ពីព្រោះលោកជាប់បំពេញទស្សនកិច្ចជួបជាមួយនឹងសហជីពសភាអន្តរប្រទេសនៅទីក្រុង ហ្សឺណែវ សភាអឺរ៉ុប ហើយ លោកនឹងលើកយកបញ្ហានេះទៅដល់អន្តរជាតិឱ្យគេជួយអន្តរាគមន៍។

លោក រ៉ុង ឈុន ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និងជាប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាបានថ្លែងនៅខាងមុខរដ្ឋសភាថា ការដកអភ័យឯកសិទ្ធិពីលោក សម រង្ស៊ី នៅពេលនេះ គឺគាំទ្រតែបំពេញតាមបំណងរបស់ប្រទេសជិតខាងប៉ុណ្ណោះ ។

ក្នុងសន្និសីទកាសែត នៅទីស្តីការគណៈរដ្ឋមន្ត្រីក្នុងថ្ងៃដដែល លោក អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានឱ្យដឹងថា មានការចោទប្រកាន់ពីបទព្រហ្មទណ្ឌបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ដែលបានដកបង្គោលព្រំដែននៃប្រទេសទាំងពីរ ។

ចំណែកលោក វ៉ា គីមហុង ប្រធានគណៈកម្មាធិការព្រំដែនបានឱ្យដឹងស្រដៀង គ្នាដែរថា ដោយសារតែលោក សម រង្ស៊ី បានបំផ្លាញ បង្គោលព្រំដែន ដែលបានចុះកិច្ចព្រមព្រៀងជាមួយ យួន ហើយបង្គោលទាំងនោះយើងបានដាំតាំងពីឆ្នាំ 2005ម្ល៉េះ ។ ប្រតិកម្មរបស់ភាគីយួនពិតជាត្រឹមត្រូវ ពីព្រោះគេបានចំណាយពេលវេលា លុយកាក់ និងបានឯកភាពគ្នាអស់ហើយ ទង្វើរបស់លោក សម រង្ស៊ី ដូចជា មើលស្រាលចំពោះគណៈកម្មាធិការព្រំដែនយើងខ្លាំងណាស់ ។

វ៉ា គីមហុង ក៏បានទទួលស្គាល់ថា ការបោះបង្គោលព្រំដែននេះវាពិតជាមានចូលដីរបស់កសិករខ្មែរ និងយួនខ្លះមែនហើយ ប៉ុន្តែវាមិនច្រើនណាស់ណាទេ ។ រហូតដល់ពេលនេះយើង បានបោះបង្គោលចំនួន128ដើម ក្នុងចំណោមបង្គោលដែលត្រូវដាំ375ដើមនោះ។

ការដែលយួនមានប្រតិកម្មខ្លាំង ហើយបានបញ្ជាឱ្យរដ្ឋាភិបាល និងរដ្ឋសភា ហ៊ុន សែន ដកអភ័យឯកសិទ្ធិលោក សម រង្ស៊ី នេះ ពីព្រោះតែចង់បង្ហែទិសដៅមិនឱ្យប្រជាពលរដ្ឋ និងមតិជាតិ-អន្តរជាតិចាប់អារម្មណ៍ចំពោះខ្លួនដែលឈ្លានពានលើទឹកដីកម្ពុជាបន្តិចម្តងៗតាំងពីយូរយារមកហើយ ។ ជាពិសេសយួន មិនចង់ឱ្យមានការសើរើរឿងព្រំដែនជាមួយកម្ពុជាទេ ខ្លាចមានអន្តរជាតិជួយអន្តរាគមន៍ និងបង្ខែរឱ្យចាប់អារម្មណ៍តែទៅលើប្រទេសស្បៃមប៉ុណ្ណោះ ។

សកម្មជនព្រំដែនដែលហ៊ានបញ្ចេញមតិរឿងព្រំដែន ត្រូវបានចាប់ខ្លួនកន្លងមកក្រុមមាន លោក រ៉ុង ឈុន, លោក កឹម សុខា អតីតប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, លោក ម៉ម សូណង់ដូ ប្រធានស្ថានីយវិទ្យុសំបុកឃ្មុំ និងមួយចំនួនទៀត បានរត់គេចខ្លួនទៅរស់នៅក្រៅប្រទេស ។

លោក ស៊ាន ប៉ែង សែ បានបញ្ជាក់ថា រឿងប្តឹងប្តល់នេះវាមិនមែនអាជ្ញាធរស្រុកខេត្តស្វាយរៀងមានសិទ្ធិប្តឹងទេ គឺទាល់តែរដ្ឋាភិបាលប្តឹង ពីព្រោះអ្នកទាំងនោះពុំដឹងច្បាស់លាស់ទេ ។ ជាពិសេស រដ្ឋសភាគួរតែបង្កើតគណៈកម្មាធិការចម្រុះទៅធ្វើការងារឱ្យបានល្អិតល្អន់ កន្លងមកសន្ធិសញ្ញាកម្ពុជា-យួនធ្វើខ្មែរបាត់បង់ដីច្រើនណាស់ ។

ជាមួយគ្នានេះដែរ សភាអឺរ៉ុប តំណាងរាស្ត្រសហរដ្ឋអាមេរិកនៅរដ្ឋកាលីហ្វ័រនីញ៉ា និងប្រធានសហគមន៍ខ្មែរ-អាមេរិក បានសម្តែងនូវការគាំទ្រសកម្មភាពរបស់លោក សម រង្ស៊ី ព្រមទាំងបានបង្ហាញពីអារម្មណ៍សោកស្តាយចំពោះការធ្លាក់ចុះនៃស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយស្នើឱ្យប្រគល់អភ័យឯកសិទ្ធិទៅលោក សម រង្ស៊ី វិញ ។

ទាក់ទងទៅនឹងឥទ្ធិពលរបស់យួនតាបសង្កត់មកលើកម្ពុជានេះត្រូវបានលោក វ៉ាន់ ឌីការអុន អតីតសមាជិកក្រុមប្រឹក្សារដ្ឋនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងជាភាសាវិទូខ្មែររស់នៅប្រទេសបារាំង បាននិយាយកាលពីថ្មីៗនេះថា យួន ដឹងច្បាស់ណាស់ថា បើ ហ៊ុន សែន គ្មានអំណាចទេ ខ្លួនក៏គ្មានឥទ្ធិពលមកលើកម្ពុជាដែរ ។

លោក វ៉ាន់ឌី ការអុន បន្តថា អំណាចរបស់ ហ៊ុន សែន នៅកម្ពុជាបច្ចុប្បន្នកំពុងជួយពង្រឹងឥទ្ធិពលរបស់យួននៅកម្ពុជាគ្មានទីបញ្ចប់ ពីព្រោះទៅណាក៏ពួកគេរំលឹកពីគុណថ្ងៃ៧ មករា 1979 ដែរ ៕

ទាមីជំនួយស្ការភាព្រសារ (ភាគ២) :

រឿងសន្សំតែក៏ៗធ្វើបានច្រើន

ដោយ : **សុស៊ីមន ចាប**

១. សន្សំដោយប្រើបញ្ជី :

អ្នកគួរចំណាយពេលខ្លះធ្វើជាបញ្ជីរាយឈ្មោះរបស់ប្រើប្រាស់ណា ដែលត្រូវការជាចាំបាច់ ឬមុខម្ហូប ឬចំណីអាហារខ្លះ ដែលគ្រួសារចូលចិត្តពិសារនៅថ្ងៃនេះ ឬសម្រាប់នៅថ្ងៃមុខឱ្យទៅតាមលេខរឿង មុននឹងអ្នកធ្វើដំណើរទៅផ្សារធ្វើរបៀបនេះ គឺជៀសវាងការទៅផ្សារញឹកញាប់ នឹងចំណាយប្រាក់កាស ដោយចិញ្ចរបស់របរខ្លះ ដែលមិនសូវជាចាំបាច់ មកតរទុកចោល. ទទួលទាន ឬប្រើប្រាស់មិនទាន់កំណត់ពេល ហើយត្រូវបោះចោលដោយឥតប្រយោជន៍ ។

២. សន្សំលើការរក្សាគុណភាពម្ហូប ឬរបស់ប្រើប្រាស់ :

អ្នកជ្រាបហើយថា ម្ហូប ឬចំណីដែលអ្នកយកពីផ្សារមក ជារបស់ដែលអ្នកបានពិនិត្យ និងជ្រើសរើសជាប្រណីត ដើម្បីរក្សាគុណភាពរបស់ទាំងអស់នោះឱ្យនៅដដែល គួរអ្នកឆ្លាប់រៀបចំទុកដាក់ដូចជា :

- សាច់គោ ឬសាច់ជ្រូក (គួរដាក់ ចូលក្នុងថង់ជ័រ Plastic ភ្លាមពេលអ្នករើសចេញពីកន្លែងត្រជាក់នៅក្នុងផ្សារ)

អ្នកគួររៀបចំចំអិនមុនគេ ឬដាក់ក្នុងទូទឹកកកផ្នែកក្រោម ជួនកាលអ្នកដាក់សាច់នេះ ក្នុងថតមួយជាប្រអប់សម្រាប់សាច់ក៏បាន ឬក៏ដាក់ក្នុងថង់ជ័រ ដែលបិទជិតក៏បាន (Ziploc) រួចដាក់ក្នុងកន្លែងកក ប្រសិនបើអ្នកទុកប្រើនៅថ្ងៃមុខ។ ការរៀបចំនេះ បើអាចធ្វើបានល្មើនមុនពីម៉ោង (ពេលយកចេញពីផ្សារ ជាការប្រសើរបំផុត ពីព្រោះមេរោគ E.Coli កើតល្មើនណាស់ ជាពិសេស សាច់ដែលមានឈាមស្រស់ៗ ដូចជា សាច់គោ ។

- **ផ្លែឈើ** :

មុននឹងពិសារ គួរអ្នកលាងទឹកឱ្យស្អាតល្អសិន ឬក៏ដាក់ក្នុងថង់ក្រដាស (Brown Bag) ដូចជា ស្វាយ ល្ហុង etc... ក្នុងភាពនៅល្អដដែលរហូតដល់ពេលដែលអ្នកត្រូវការពិសារក្នុងរយៈពេលមួយទៅពីរអាទិត្យ ។

- **បន្លែ** :ដែលអ្នកបំរុងទុកពិសារទៅថ្ងៃមុខ ដូចជា ត្រឡាច ត្រសក់ etc... ដាក់រុំដោយក្រដាស កាសែត ឬក្រដាសផ្សាយពាណិជ្ជកម្មផ្សេងៗ ឬក៏ ថង់ក្រដាស (Brown Bag) រួចរៀបទុកដាក់ឱ្យល្អ ក្នុងទូទឹកកក គុណភាពនៅល្អបានយូរជាងដាក់ក្នុង ថង់ជ័រ Plastic ដែលដោយតាមមកពីផ្សារជាមួយ ។

ល្បិចគួរចាំ : បន្លែ ដូចជា សាឡាត ឬជី អ្នកបានលាងទឹកស្អាតល្អហើយ តែប្រើមិនទាន់អស់ គួរយកក្រដាសស្ងួត (Bounty) មករុំឱ្យជុំ (ជូតគល់និងជូតសន្លឹក) រៀបចំក្នុងទូទឹកកកក់ឱ្យស្រួល គុណភាពនឹងនៅល្អបានច្រើនថ្ងៃទៀត ។

៣. សន្សំដោយប្រើពេលវេលាចាំ :

បើសិនជាអ្នកមានបំណងរកសំល្បែកបំពាក់ណាល្អ គុណភាព និងតម្លៃខ្ពស់ ឬជារបស់ប្រើប្រាស់ល្អៗ ក្រាន់បើ គួរអ្នកតាំងចិត្តអត់ធ្មត់បន្តិច ដោយរង់ចាំមើលពេលវេលាណាហាងលក់របស់នោះផ្សាយដំណឹងលក់ចុះថ្លៃ តែគួរកត់សំគាល់ថា របស់អស់នោះគេលក់ចុះថ្លៃទៅតាមតម្លៃរបស់ដែលមានឈ្មោះល្បី (Brian Name) ដែរ ។ ដូចជា នៅថ្ងៃទី ១៨ ខែតុលា កន្លងទៅនេះ Macy´s មានលក់វត្ថុយ៉ាងច្រើន ចុះថ្លៃ "ពិសេស" ពីម៉ោង ៨:00 ព្រឹក រហូតដល់ម៉ោង ១២:00 ថ្ងៃត្រង់ :

- 50% off ក្រោម ពីតម្លៃដើម
- 20% off ក្រោម ចុះថ្លៃបន្ថែម បើអ្នកប្រើក្រេឌីត ខត "ម៉េស៊ី" (Macy´s Credit Card)
- 20% off ចុះថ្លៃបន្ថែមទៀត បើអ្នកមាន គូប៉ុង "ម៉េស៊ី" (Macy´s Coupon)

ដូចជា ក្រវិលដាំតុជ (Culture Pearl Earing) មួយគូរតម្លៃដើម :

- $140 → 50% ចុះដល់ $70
- $70 → 20% បន្ថែម ចុះដោយប្រើ ក្រេឌីត ខត
- $56 → 20% បន្ថែមទៀត ដោយប្រើ គូប៉ុន ចុះមកដល់ - $45 គឺជាតម្លៃចុងក្រោយបំផុត ឃើញថាអ្នកសន្សំបានប្រាក់ក្នុងចំនួន ដែលអាចចំណាយទៅលើរបស់អ្វីផ្សេងៗទៀតបាន ឬក៏ទុកសន្សំដាក់កូនជ្រូក (Home Banking) ។

នៅពេលខ្លះទៀត អ្នកគួរចំណាយដើរអើតតាមហាងលក់ផ្សេងៗទៀត ដូចជា វ៉លម៉ាត " Wal Mart" ថ៉ាគ្លែត "Target" etc... ឬក៏ទៅដល់ដុល្លារស្ទ័រ (Dollar Store) ជួនកាលអ្នកក៏អាចប្រទះ របស់ខ្លះមានគុណភាពគួរសម ដែលអាចប្រើប្រាស់បានមួយរយៈដែរ ដូចជា កំរាលតុ ក្រាលពេលជប់លៀងមួយភ្លែត ហើយបោះចោល ឬក៏ក្រដាសខ្ចប់របស់ផ្សេងៗសម្រាប់ពេល ដូចជា រង្វាន់ត្រីស្មាស់ (Christmas gift) ឬរង្វាន់ថ្ងៃកំណើត (Birthday gift) សម្រាប់កូនក្មេង ពួកក្មេងគេចង់ឃើញតែ របស់ដែលនៅក្នុងកញ្ចក់ទេ ដូច្នេះ ការចំណាយក៏ស្រួលដែរ ។

៤. សន្សំការចាយលើថាមពលកំដៅផ្ទះ (Heat)

រដូវត្រជាក់ធ្លាក់មកហើយ មុនបើកកំដៅ (heat) ក្នុងផ្ទះ អ្នកគួរពិនិត្យមើលតាមបង្ហួច និងតាមទ្វារតាមកញ្ចក់បិទ. ដាក់កន្ទីសឱ្យជាប់ ហើយពិនិត្យមើលកន្លែងផ្សេងទៀត ដែលមានខ្យល់ត្រជាក់ចូលបង្ហួច ដាក់កន្ទីសមិនចូល ឬមានចន្លោះប្រហោង ។ អ្នកអាចទៅរកប្រដាប់ជួសជុលបង្ហួចមានប្រហោង (Window Insulation Kill) នៅហាង "Home Depot" ឬក៏ "Lowe´s" នៅក្នុងកញ្ចប់នោះ មានផ្ទាំងជ័រ Plastic ចំនួនបី 42"ទទឹង និង 62" បណ្តោយ រួមជាមួយ Tape ស្អិត ទំហំតូច ភ្ជាប់ ជាមួយ មានតម្លៃ $4.48 ផ្ទាំង Plastic នេះអ្នកអាចដាក់ពីលើបង្ហួចទាំងមូលបាន ដោយប្រើ Tape ទំហំតូចបិទពីខាងក្នុង. ជុំវិញបរិវេណបង្ហួចរួចហើយ អ្នកអាចបិទ Tape ទំហំធំបន្តិច ដែលប្រើទាំងខាងក្នុង និងខាងក្រៅ មានតម្លៃ ១ដុំ $7.69 បិទថែម ពីលើជាយផ្ទាំងជ័រ Plastic នោះទៀត ជាការជំនួយ ឱ្យបានកាន់តែជាប់ខ្លាំងនៅពេលដែលមានខ្យល់បក់វៃខ្លាំងម្តងៗ ។

ជាបន្ថែមទៀត អ្នកគួរយកភួយក្រាស់ បត់ដាក់តាមជើងបង្ហួច ឬទ្វារ ធ្វើដូច្នេះដើម្បីការពារកុំឱ្យត្រជាក់ពីខាងក្រៅចូលមកក្នុងផ្ទះ និងខះឃាត់កំដៅក្តៅក្នុងផ្ទះជ្រាបចេញទៅក្រៅបាន ។

ម្យ៉ាងវិញទៀត ជៀងវាងការបើកទ្វារចេញ ឬចូលដោយចំហរចោលយូរពេក ។

នៅពេលថ្ងៃ បើគ្មាននរណានៅក្នុងផ្ទះ ដូចជា កូនចៅអ្នកចេញទៅរៀន ឬអ្នកចេញទៅធ្វើការអស់ គួរបន្ថយកំដៅចុះមក 62-64 អង្សា ។ ធ្វើដូច្នេះដែរ នៅពេលយប់ នៅពេលអ្នកនឹងគ្រួសារចូលសំរាន្តអស់ ពីព្រោះអ្នកមានសំល្បែកបំពាក់សំរាន្តក្រាស់ៗ ល្មមហើយ និងសល្តប់ភួយក្រាស់ទៀត ។

បន្ទាប់ពីការប្រុងប្រៀប និងប្រុងប្រយ័ត្នដោយអស់សមត្ថភាព អ្នកនឹកឃើញថា តម្លៃប្រើកំដៅ (heat) ប្រចាំខែមានភាពខុសប្លែកជាមិនខាន ។

ល្បិចគួរចងចាំ : ពេលថ្ងៃ បើអ្នកនៅផ្ទះតែម្នាក់ឯង គួរប្រើគ្រឿងកំដៅជំនួយ (កូន Electric heat) វិញ សម្រាប់នៅក្នុងបន្ទប់ដែលអ្នកសំរាក. សំរាន្ត ឬប្រកបការងារផ្សេងៗ រួមផ្សំជាមួយសំល្បែកបំពាក់ក្រាស់ល្មម ។

អ្វីៗដែលអ្នកបានប្រតិបត្តិតាមការណែនាំដូចខាងលើនេះរួចហើយ អ្នកនៅតែមានអារម្មណ៍ថា ខ្យល់ត្រជាក់នៅតែចូលមកច្រើនដដែល ឯកំដៅខាងក្នុងនៅតែមិនគ្រប់គ្រាន់ អ្នកគួរតែពិនិត្យទៅជញ្ជាំងផ្ទះម្តង ពីព្រោះជាតិស៊ីម៉ង់ត៍ដែលផ្សារភ្ជាប់តគ្នាពីដុតដួមួយទៅដុំមួយទៀតនោះ ប្រហែលជាពុកផុយ ឬជ្រុះអស់ ធ្វើឱ្យមានជាប្រហោង។ នេះជាកន្លែងធ្វើឱ្យខ្យល់ត្រជាក់ចូលបាន និងកំដៅក្តៅចេញបានយ៉ាងស្រួលដូច្នេះការជួយជុលក៏ត្រូវការជាបន្ទាប់ ។

5. សន្សំប្រាក់ចំណាយលើអគ្គីសនី :

នៅក្នុងរដូវត្រជាក់នេះ អ្នកមិនត្រឹមតែចំណាយទៅលើថ្លៃប្រើកំដៅ heat (Oil, Gas) ច្រើនទេ ទន្ទឹមគ្នានោះ អ្នកក៏ត្រូវចំណាយទៅលើថ្លៃអគ្គីសនីច្រើនដែរ ពីព្រោះទាំងពីរនេះ ដើរកាន់ដៃគ្នាជាប់ជានិច្ច មិនអាចបំបែកគ្នា ជាពិសេសក្នុងរដូវនេះ គឺ heat (Oil, Gas) ត្រូវការចន្លគអគ្គីសនីជាចាំបាច់ តែអគ្គីសនីអាចរត់បានដោយខ្លួនឯង ជាពន្លឺផង ជាកំដៅផង ។

ក៏ប៉ុន្តែក្នុងការប្រើប្រាស់អគ្គីសនី ក៏ត្រូវការរវាសរវៃប្រុងប្រយ័ត្នឱ្យបានមាំមួនដែរ ។

- នៅពេលអ្នកប្រើកូន Electric heat ជាជំនួយ អ្នកត្រូវបិទកុងតាក់ និងដកខ្សែចេញពីជញ្ជាំង នៅពេលអ្នកឈប់ប្រើ ឬក៏អ្នកត្រូវចាក់ ចេញពីតំបន់នោះ ឬបន្ទាប់នោះមួយរយៈ ។ ដើម្បីរក្សាសន្តិសុខ គឺភ្លើងនេះ ឬត្រូវចំណាយចរន្តអគ្គីសនីរត់ចោល ។

Ex : ដែកមូរសក់ ឬឆ្នាំងអ៊ុតសំល្បែកបំពាក់ អ្នកមូលបិទកុងតាក់មែន តែចំណុចភ្លើងក្រហមនៅតែឆេះ នេះបញ្ជាក់ថា ចរន្តអគ្គីសនីនៅតែបន្តសកម្មភាពដដែល ។

- នៅតំបន់ណា ឬក៏បន្ទប់ណាដែលអ្នក ឬគ្រួសារអ្នកអង្គុយលេង ឬក៏ធ្វើសកម្មភាពអ្វីផ្សេងៗ គួរប្រើភ្លើងភ្លឺចុះ តែបន្ទប់ផ្សេងៗទៀត គួរពន្លត់សិន ឬក៏ប្រើពន្លឺតូចជំនួសវិញ ។

Ex : អ្នក និងគ្រួសារអ្នកកំពុងទទួលទានអាហារពេលល្ងាច ឬកំពុងទស្សនាភាពយន្តក្នុងបន្ទប់ទទួលទាន ឬបន្ទប់សម្រាប់គ្រួសារ ពេលនោះបន្ទប់ផ្សេងៗឯទៀត អ្នកគួរពន្លត់ភ្លើងសិន ។ **តទៅទំព័រទី ១៦**

From :Philadelphia

សួស្តីឆ្នាំថ្មី

ហាងខ្ញុំរដ្ឋសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe`s Auto Service

State and Emission
Inspection General
Repairs and Maintenance
MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដួរប្រេង ដួរប្រាំង ដួរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យត្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដួរប្រេងកីរ៉ត ៥ ក្ឋាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់-មានជូនប័ណ្ណពិសេស សំរាប់ដួរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

នយោបាយខ្មែរ

១_"សេចក្ដីថ្លែងការណ៍របស់គណបក្សសិទ្ធិមនុស្ស"

•••នាឱកាសខួបទី ១៨ នៃសេចក្ដីប្រកាសជាសកល ស្ដីពីសិទ្ធិមនុស្ស ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១០ ធ្នូ នេះ គណបក្សសិទ្ធិមនុស្សនៅកម្ពុជា បានចេញសេចក្ដីថ្លែងការណ៍មួយ ពិពណ៌នាអំពីការគោរពសិទ្ធិនៅក្នុងប្រទេសថា :

. សិទ្ធិជាមូលដ្ឋាន :

សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដូចជា សិទ្ធិមានអាហារ សិទ្ធិមានលំនៅដ្ឋាន សិទ្ធិទទួលការថែទាំសុខភាព សិទ្ធិទទួលការសិក្សា សិទ្ធិមិនរើសអើងនយោបាយ សិទ្ធិបញ្ចេញមតិ ការរើសអើងពលរដ្ឋខ្មែរកម្ពុជាក្រោមជាដើម ។ល។ ប្រជាពលរដ្ឋត្រូវបានប្រឈែីយកន្ដើយពីសំណាក់សមត្ថកិច្ច និងអ្នកមានអំណាច និងមាសប្រាក់ជាក់ស្ដែងការបណ្ដេញចេញពីលំនៅដ្ឋាន នៅតំបន់ដីក្រហម បឹងកក់ រាជធានីភ្នំពេញ និងខេត្តមួយចំនួន ដូច ជា ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកំពត ការផ្សឹកព្រះ សង្ឃ ទីម សាខន ហើយបញ្ជូនទៅឱ្យឃុនធ្វើការកាត់ទោស ។ល។ សិទ្ធិបញ្ចេញមតិរឹតតែទទួលនូវការគំរាមកំហែងខ្លាំងឡើង។ជាលំដាប់ សូម្បីតែអ្នកតំណាងរាស្ត្រ ដែលមានសម្លេងភាគតិចនៅរដ្ឋសភា ក៏ក្រុមអ្នកមានអំណាច និងមានសម្លេងភាគច្រើនបង្កើតច្បាប់ផ្សេង។ រារាំងមិនឱ្យអស់លោកអាចបំពេញតួនាទីរបស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញបានដែរ ។

. ការប្រើអំណាចតុលាការ :

ការប្រើតុលាការ ដែលពុំមានលក្ខណៈអព្យាក្រឹត្យ ដើម្បីបំបិទមាត់អ្នកជំទាស់ ការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រយ៉ាងងាយ។ រួមទាំងការចាប់អ្នកការសែតមួយចំនួនដាក់ពន្ធនាគារ គឺជាសក្ខីកម្មបង្ហាញថា ប្រទេសកម្ពុជា កំពុងតែរំកិលខ្លួនបន្ដិចម្ដង។ទៅរកលទ្ធិផ្ដាច់ការដូចមុនឆ្នាំ ១៩៩១ ។

គណបក្សសិទ្ធិមនុស្សស្នើឱ្យម្ចាស់ជំនួយ ជួយកែតម្រូវការអនុវត្តន៍សិទ្ធិមនុស្សនៅកម្ពុជាយ៉ាងនេះថា :

- ត្រូវលើកកំពស់សិទ្ធិបញ្ចេញមតិឱ្យបានប្រសើរ ដោយត្រូវធ្វើវិសោធន៍កម្មច្បាប់ ដែលបានកិរតសិទ្ធិអ្នកតំណាងរាស្ត្រ និងពលរដ្ឋ និងបញ្ឈប់ការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រយ៉ាងងាយ។នោះចោលចេញ ត្រូវកែប្រែប្រព័ន្ធតុលាការឱ្យមានឯករាជ្យភាពពិតប្រាកដ មិនមែនឯករាជ្យតែរូបភាពដូចសព្វថ្ងៃនេះទេ ។

ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ត្រូវចេញឱ្យបានយ៉ាងឆាប់បំផុត ហើយបើយ៉ាងយូរណាស់នៅត្រឹមត្រីមាសទី២ ឆ្នាំ២០១០ និងសូមឱ្យមានអនុភាពប្រតិសកម្មផង ។

- បញ្ឈប់ការដេញប្រជាពលរដ្ឋ ដោយយកលេសអភិវឌ្ឍន៍បែបក្លែងក្លាយបែបនេះតទៅទៀត ។ ករណីដែលមានប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋគឺត្រូវផ្ដល់សំណងជូនពួកគាត់ជាមុនឱ្យបានសមរម្យផង។

- បញ្ឈប់ការរើសអើងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលបានមករស់នៅកម្ពុជា និងគប្បីផ្ដល់សិទ្ធិជូនពួកគាត់ឱ្យដូចជាពលរដ្ឋខ្មែរទូទៅដែរ ។

២_ទស្សនៈកិច្ចសមាជិកសភាគណបក្សសម រង្ស៊ី នៅខេត្តស្វាយរៀង

សមាជិក ២១នាក់ នៃគណបក្ស សម រង្ស៊ី បានអញ្ជើញទៅពិនិត្យបង្គោលព្រំដែនកម្ពុជា-វៀតណាម នៅតំបន់ រំដួល និង ចន្ទ្រា កាលពីថ្ងៃទី ១៤ ធ្នូ ២០០៩ កន្លងទៅ ។ កងប៉ូលិស បានធ្វើការរាំងស្ទះដំណើរក្រុមអ្នកធ្វើច្បាប់នៃគណបក្សប្រឆាំង និងបណ្ដាអ្នកស្រុកដែលហែរហមដំណើរយ៉ាងតូរឱ្យព្រួយបារម្ភចំពោះសន្ដិសុខប្រជាជន និងអ្នកធ្វើច្បាប់ ។

សមាជិកសភាទាំងនោះ បាននិយាយប្រាប់កាសែតភ្នំពេញប៉ុស្ដិ៍ថា "ការបោះបង្គោលនៅកណ្ដាលដីស្រែអ្នកស្រុកមានការខ្វះតម្លាភាពពីភាគីទាំងសងខាង" - រីឯលោក វ៉ា គឹមហុង តំណាងអង្គការព្រំដែនវប្បកិបាលខ្មែរ និយាយតបថា "សមាជិកសភារបស់គណបក្សប្រឆាំងអាចទៅព្រំដែនបាន តែមិនត្រូវបំផ្លាញសម្បត្តិរដ្ឋទេ !" ហើយលោកបន្ដថា "តែដំបង្គោលវាប៉ះពាល់ដីស្រែហើយ បើអ្នកស្រុកមិនចង់ឱ្យប៉ះ អ្នកឯងទៅដាំស្រូវនៅលើមេឃទៅ ! "

តទៅនៅជារូបភាពដកស្រង់ពី វេបសាយ គណបក្សសម រង្ស៊ី ៕

ក្ដីសង្ឃឹមរបស់អ្នកប្រជាធិបតេយ្យមានពន្លឺព្រឿងៗ

ដោយ : អ៊ុមលឿម

•••រហូតមកដល់ពេលនេះ "សម្ព័ន្ធអ្នកប្រជាធិបតេយ្យដើម្បីការផ្លាស់ប្ដូរ" ដែលបានបង្កើតរួមគ្នារវាងគណបក្ស សម រង្ស៊ី ដឹកនាំដោយលោក សម រង្ស៊ី ផ្ទាល់ និងគណបក្សសិទ្ធិមនុស្ស ដែលដឹកនាំដោយលោក កឹម សុខា ហាក់គ្មានសញ្ញាជាវិជ្ជមានណាមួយ ដែលបង្ហាញពីផ្លែផ្កាបានអំពីការរួបរួមគ្នា រវាងគណបក្សទាំងនេះនៅឡើយ បើទោះបីជាគណបក្សប្រឆាំងទាំងពីរ នៅតែរក្សានូវនិរន្ដរភាពជាអ្នកប្រជាធិបតេយ្យរួមគ្នា និងពុំដែលបង្កនូវភាពប្រេះឆារវាងគ្នានឹងគ្នាយ៉ាងណាក៏ដោយចុះ ។

គេនៅចងចាំយ៉ាងច្បាស់ថា ទាំងគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សធ្លាប់បានចេញសេចក្ដីថ្លែងការណ៍ជាចំហរថា : នឹងរួបរួមគ្នាបង្កើតគណបក្សថ្មីមួយ ដើម្បីត្រៀមយកជ័យជំនះក្នុងការបោះឆ្នោតជាសកលនៅឆ្នាំ ២០១៣ ខាងមុខ លើគណបក្សប្រជាជនកម្ពុជា ដែលកំពុងក្ដោបក្ដាប់អំណាចរបស់ខ្លួនអស់ប៉ែទសវត្សរ៍មកហើយនោះ ។

ក៏ប៉ុន្ដែបើយោងតាមប្រភពព័ត៌មាន អាចយកជាការបានមួយចេញពីសាខាគណបក្សសិទ្ធិមនុស្សប្រចាំសហរដ្ឋអាមេរិក ដែល **ខ្មែរប៉ុស្ដិ៍** ទទួលបានកាលពីពេលថ្មីកន្លងមកនេះ បានឱ្យដឹងថា : "គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស អាចនឹងច្របាច់បញ្ចូលគ្នាជាគណបក្សតែមួយ នាពេលដ៏ខ្លីខាងមុខនេះ " ។ ក៏ប៉ុន្ដែ ក្នុងគ្រាដំណាលគ្នានោះ អ្នកនាំពាក្យរបស់គណបក្ស សម រង្ស៊ី គឺលោក យឹម សុវណ្ណ បានថ្លែងថា "គណបក្ស សម រង្ស៊ី នៅពុំទាន់បានគិតដល់ពីការច្របាច់បញ្ចូលរួមគ្នាជាមួយគណបក្សសិទ្ធិមនុស្សដើម្បីបង្កើតជាគណបក្សតែមួយនោះនៅឡើយ តែគណបក្ស សម រង្ស៊ី នៅពុំងាករេ ក្នុងការធ្វើបញ្ជីឈ្មោះបេក្ខជនរួមគ្នាសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ នាឆ្នាំ ២០១២ ខាងមុខនេះឡើយ " ។

បើយោងតាមប្រភពព័ត៌មានដោយឡែកមួយទៀត ធ្លាយចេញពីប្រធានសាខាគណបក្សសិទ្ធិមនុស្សប្រចាំទ្វីបអាមេរិកខាងជើង គឺលោក ញ៉ុយ ចំរើន បានឱ្យ **ខ្មែរប៉ុស្ដិ៍** ដឹងថា : " គណបក្សហ៊ុនស៊ុនប៊ិច និងគណបក្ស នរោត្ដម រណឫទ្ធិ ក៏នឹងត្រៀមខ្លួនចូលជាមួយគណបក្សសិទ្ធិមនុស្សផងដែរ ។ ហើយគណៈបក្សទាំងពីរនេះ ក៏នឹងដាក់ចិត្ដដាក់កាយក្នុងការឱ្យលោក កឹម សុខា **តទៅទំព័រទី ១៨**

ANGKOR AUTO SERVICE, INC.
ហាងជួសជុលរថយន្ដ "អង្គរ"
4835 N. 16th Street. Tel : (215) 455-7810
Philadelphia, Pa 19141 Ricky : (215) 485-1425
Specializing in Body Kit and Custom Paint
ជំនាញខាងជួសជុលតួរថយន្ដ
និងបាញ់ថ្នាំជាក់ក្បាច់តាមចំណង់ចំណូលចិត្ដ
RICKY
Hand Phone Ricky 215-485-1425
មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្ដមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ីនស៊ួរិន បានផង
យើងផ្ដល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C
មុនពេលជួសជុល
ក្រោយពេលជួសជុល
បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

Leema's 168 Market
5010 Old York Rd, Philadelphia, PA 19141-2707
Contact Phone: (215) 455-1003
ផ្សារ លីម៉ា 168

A.B.C MONEY TRANSACTION, INC

ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

		ភ្នំពេញ	តាមខេត្ត
ផ្ញើ $100	យកកម្រៃ	$4.50	$5.50
$200	យកកម្រៃ	$9.00	$11.00
$300	យកកម្រៃ	$13.50	$16.50
$500	យកកម្រៃ	$16.00	$17.00
$1000	យកកម្រៃ	$25.00	$26.00
$1500	យកកម្រៃ	$35.00	$36.00
$2000	យកកម្រៃ	$42.00	$43.00
$2200	យកកម្រៃ	$46.00	$47.00

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

នៅរដ្ឋ VIRGINIA សូមទាក់ទង

ABC MONEY TRANSATION ,INC.

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

ARIZONA
- ◆4215 N 19th Ave. . Tel : 602.266.6744

GEOERGIA
- ◆ 4897 Buford Hwy. Ste. 202. Tel: 770.457.7888

ILLINOIS
- ◆4871 N. Broadway . Tel :773.989.7332

MASSACHUSETTE
- ◆ 996 Dorchester Ave. Tel:617.825.9380
- ◆ 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

MINNESOTA
- ◆ 2718 Nicollet Ave . S.- Ste. 102 B
- ◆ Tel : 612.871.4731
- ◆ 6350 Brooklyn Blvd . Tel : 763.503.3947

NORTH CAROLINA
- ◆ 3000 Central Ave. Ste . #9 . Tel : 704-532-4420

OREGON
- ◆6908 N.E. Sandy Blvd . Tel : 503.281.8088

PHILADFELPHIA
- ◆5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
- ◆571 Adams Ave . Ave.#4 . Tel : 215.342.6623

TEXAS
- ◆1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
- ◆2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
- ◆5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
- ◆3538 W . Walnut St. Tel : 972.272.2253
- ◆11205 Bellaire Blvd . Tel : 281.561.6600
- ◆10909 Scarsdale Blvd . Tel : 281.481.2700
- ◆13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

WASHINTON STATE
- ◆766 S.38th St,. Tel : 253.475.2847
- ◆3818 S.Graham St.-Ste. C Tel : 206.721.2070

ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្តាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ (NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

(តមកពីទំព័រទី ០៣)

កូនខ្មែរដើបូងគេក្នុងប្រវត្តិសាស្ត្រ...

នៅទីក្រុង Lowell រដ្ឋម៉ាហ្សាឈូសេត នាពេលខាងមុខ ។ យើងត្រូវមានសម្លេងជាតំណាងរបស់ខ្មែរ-អាមេរិកាំងនៅគ្រប់រចនាសម្ព័ន្ធរដ្ឋាភិបាលតាំងពីថ្នាក់ក្រុង ថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធ ។ ការផ្តល់ការងារ និងឱកាសកសាងសេដ្ឋកិច្ចសម្រាប់ពលរដ្ឋខ្មែរ-អាមេរិកាំង ជាមួយនឹងការបង្កើនគុណភាព និងសេវាកម្មផ្នែកវិស័យ សិក្សាធិការសម្រាប់កូនខ្មែរក្នុងសង្គមខ្មែរ-អាមេរិកាំង ដោយធ្វើយ៉ាងណាឱ្យកូនខ្មែរ ទទួលបានការសិក្សាយ៉ាងហោចណាស់បានបញ្ចប់ថ្នាក់មធ្យមសិក្សានៅវិទ្យាល័យ ។ ដោយធ្វើសកម្មភាពអប់រំក្នុងការកាត់បន្ថយអត្រាមានផ្ទៃពោះនៃយុវនីតិជន ។

មាស សែម ថ្លែងយ៉ាងមុតមាំថា "**ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងមានមោទនភាពដើម្បីបង្ហាញប្រាប់បងប្អូនថា ខ្លួនខ្ញុំ គឺជាជនជាតិខ្មែរ-អាមេរិកាំង ដំបូងក្នុងប្រវត្តិសាស្ត្រ ដែលបានឈរឈ្មោះជាបេក្ខជនសភាតំណាងរាស្ត្រអាមេរិកនៅក្នុងមណ្ឌលទី៥នៃរដ្ឋម៉ាហ្សាឈូសេត ខ្ញុំសង្ឃឹមថា បេក្ខភាពរបស់ខ្ញុំ គឺជាភាពជោគជ័យរបស់ខ្មែរ និងជាជោគជ័យរបស់អ្នករាល់គ្នា ហើយក៏ជាជ័យជំនះរបស់យើងគ្រប់គ្នាជាជនជាតិខ្មែរ-អាមេរិកាំងដែលរស់នៅលើទឹកដីអាមេរិក ។ ខ្ញុំនឹងជាតំណាងរបស់អ្នករាល់គ្នានៅក្នុងសភាអាមេរិកាំង... ខ្ញុំនឹងខិតខំធ្វើការដើម្បីផលប្រយោជន៍អ្នករាល់គ្នា... ហើយសំឡេងរបស់ជនជាតិខ្មែរយើងនឹងមិនត្រូវបាននរណាម្នាក់ធ្វើមិនដឹងមិនឮបានទៀតឡើយ**" ។

មាស សែម បានអំពាវនាវទៅដល់បងប្អូនខ្មែរជាទូទៅក្នុងន័យយ៉ាងដូច្នេះថា "ដើម្បីឱ្យខ្ញុំអាចធ្វើការបម្រើអ្នកទាំងអស់គ្នា និងដើម្បីឱ្យរូបខ្ញុំក្លាយទៅជាតំណាងពេញសិទ្ធិរបស់អ្នកទាំងអស់គ្នា គឺខ្ញុំត្រូវការការចូលរួម និងជ្រោមជ្រែងពី សំណាក់បងប្អូនទាំងអស់គ្នា ដោយខ្ញុំចង់ឮពីសម្លេង កង្វល់ និងសេចក្តីត្រូវការរបស់បងប្អូន ។

អ្នកនយោបាយជើងចាស់ ខ្មែរ-អាមេរិកាំង ម្នាក់ដែលបាន ចូលនិវត្តន៍ កាលពី5ឆ្នាំមុននៅ តំបន់ Washington, D.C មិនចង់បញ្ចេញឈ្មោះបានប្រាប់ ខ្មែរប៉ុស្ដិ៍ ឱ្យដឹងថា ការគាំទ្រថវិកា និងស្មារតីចំពោះ កូនខ្មែរជំនាន់ក្រោយ ដែលជាប្រវត្តិសាស្ត្រទី១របស់ជនជាតិខ្មែរ-អាមេរិកាំង គឺចាំបាច់ណាស់ពីយើងជាពលរដ្ឋខ្មែរ-អាមេរិកាំង ទាំងអស់គ្នាត្រូវជំរុញសាមគ្គី និងគាំទ្រដើម្បីប្រយោជន៍ខ្មែរទាំងមូល មិនមែនដើម្បីប្រយោជន៍បុគ្គល សែម មាស ម្នាក់ឯងនោះទេ ។ ដោយយើងកុំទាន់គិតបែងចែកខ្មែរនេះ... ខ្មែរនោះ... កើត ឬមិនកើត ពោល គឺធ្វើយ៉ាងណាឱ្យពាក្យថា ខ្មែរ... ជនជាតិខ្មែរ... លេចធ្លោមានកិត្តិយស មានសំឡេងក្នុងអំណាចរដ្ឋាភិបាលអាមេរិកាំងសិន ។

អ្នកនយោបាយជើងចាស់រូបនេះបានបន្តប្រសាសន៍ថា ការជួយជ្រោមជ្រែងសម្រាប់យុទ្ធនាការរបស់មាស សែម ពីបងប្អូនខ្មែរ មិនថាក្នុង ឬក្រៅរដ្ឋ និងបណ្តាជនជាតិអាស៊ី-អាមេរិកាំងផ្សេងទៀត គឺជាគន្លឹះនាំឱ្យរូបគេ (មាស សែម) នឹងឈ្នះឆ្នោត ។

បងប្អូនខ្មែរដែលបានចូលរួមក្នុងពិធីនោះ បាននាំគ្នាឆ្លើយនឹងសំណួរខ្មែរប៉ុស្ដិ៍ឱ្យដឹងថា ពួកគេរីករាយគាំទ្របេក្ខជន មាស សែម ព្រោះចង់ឃើញកូនខ្មែរជំនាន់ក្រោយជួយលើកស្ទួយជាតិខ្មែរឱ្យមានមុខមាត់កិត្តិយសឱ្យបានប្រពៃនៅក្នុងរដ្ឋាភិបាល រដ្ឋសភារបស់ប្រទេសអាមេរិក ដើម្បីកុំឱ្យខ្មាសជាតិសាសន៍គេដែលជាជនជាតិអាស៊ីដូចគ្នា ហើយចំណាកស្រុកដូចគ្នា ពួកគេខំប្រឹងរហូតបានដល់ធ្វើការចំ១នៅសេតវិមានរដ្ឋសភា មានតំណាងរាស្ត្រ ព្រឹទ្ធសភា ដូចជា ជនជាតិយួន ចិន ម៉ុង ជាដើម ។ ដូច្នេះសូមឱ្យខ្មែរ-អាមេរិកាំងរួបរួមគ្នាជួយគាំទ្រគ្នាក្នុងនាមខ្មែរតែមួយ ជាតិតែមួយ ទោះបីការជួយជាជំនួយតិចក្តី ឬច្រើនក្តី ។

ក្នុងឱកាសនោះបេក្ខជន មាស សែម បានដាក់ការសន្យាថា "នៅពេលខ្ញុំក្លាយជាអ្នកតំណាងរាស្ត្រសភាអាមេរិកាំង ខ្ញុំនឹងខិតខំធ្វើការកែទម្រង់វិស័យសុខភាព ដែលជាតម្រូវការចាំបាច់ទាមទារឱ្យមានដំណើរការកំណែទម្រង់ពិតប្រាកដ ពោល គឺមិនមែនអ្វីដែលរដ្ឋសភា និងប្រធានាធិបតីបាននឹងកំពុងធ្វើនាពេលសព្វថ្ងៃនេះទេ ។ ដូចជាដំណោះស្រាយពិតប្រាកដអំពីតម្លៃនៃការថែទាំសុខភាព ការធានារ៉ាប់រងផ្នែកសុខភាពដែលអាចជួយដល់អ្នកក្រីក្រគ្រប់គ្នានៅទូទាំងប្រទេសអាមេរិក និងការបង្ហាញឱ្យឃើញនូវការប្រកួតប្រជែងនៃឧស្សាហកម្មថែទាំសុខភាពដែលជាតម្រោងច្បាស់លាស់ និងតម្លៃថោក" ។

មាស សែម បានប្រមើលមើលក្នុងចំណាត់ការឱ្យដឹងថា អត្រាអ្នកអត់ការងារធ្វើចំនួន 10% នៅទូទាំងប្រទេស ព្រោះតែការធ្លាក់ចុះនៃវិបត្តិ សេដ្ឋកិច្ចនៅអាមេរិក និងពិភពលោកនោះ ។ មាស សែម បានដាក់ការសង្ឃឹមថា យើងពិតជាអាចដោះស្រាយបានពីវិបត្តិនេះ ដោយផ្តល់នូវការលើកទឹកចិត្តចំពោះការបង់ពន្ធ និងកញ្ចប់ថវិកាសម្រាប់វិស័យពាណិជ្ជកម្មខ្នាតតូច។ ។ ដោយយើងមិនអាចអនុវត្តការប្រមូលពន្ធដូចរដ្ឋបាលលោកប្រធានាធិបតី Obama និងសភាដែលត្រួតត្រាដោយពួកបក្សប្រជាធិបតេយ្យនាពេលបច្ចុប្បន្ននេះទេ ។ ជាមួយនឹងកំណែទម្រង់អប់រំបញ្ហាអន្តោប្រវេសន៍ទាក់ទងនឹងការបញ្ជូនកូនខ្មែរត្រឡប់ទៅកម្ពុជាវិញ និងការយកចិត្តទុកដាក់សម្រាប់មនុស្សចាស់ជាខ្មែរ-អាមេរិកាំងជាដើម ។

ជុំវិញបញ្ហានៃការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រសភាអាមេរិករបស់ មាស សែម មតិពីមជ្ឈដ្ឋានមហាជនមួយចំនួនបានមើលឃើញថា បងប្អូនខ្មែរនៅអាមេរិកមានចំនួនមិនជាច្រើនលើសលុបឡើយ ដែលបានក្លាយខ្លួនទៅជាពលរដ្ឋអាមេរិកាំង ដោយភាគច្រើននៅកាន់ Green Card ។ ហើយអ្នកចូលសញ្ជាតិអាមេរិកនោះទៀត ហាក់មិនសូវចាប់អារម្មណ៍ពីរឿងនយោបាយនៅក្នុងសហរដ្ឋអាមេរិក ដោយមិនខ្វល់ខ្វាយពីបញ្ហាការទៅបោះឆ្នោត ដែលនេះជាបញ្ហា ? ហើយធ្វើឱ្យសំឡេងខ្មែរយើងបែរជាមានតិចទៅវិញក្នុងអត្រាស្ថិតិចុះឈ្មោះបោះឆ្នោត ។ ក្នុងខណៈដែលខ្មែររស់នៅសហរដ្ឋអាមេរិកមានជាង 40ម៉ឺននាក់ ។ ដូច្នេះក្នុងនាមសហគមន៍ខ្មែរនីមួយៗ ត្រូវគិតពីបញ្ហាចូលសញ្ជាតិការយល់ដឹងពីសារៈសំខាន់ពីនយោបាយអាមេរិក ទៅនឹងការបោះឆ្នោត ដោយមិនត្រូវលើកយកបញ្ហានយោបាយនៅកម្ពុជា មកប្រៀបប្រដូចទៅនឹងសង្គមអាមេរិកនោះទេ ។

ontime staffing
HireSatisfaction™

បុគ្គលិកទាន់ពេល ជ្រើសរើសយ៉ាងពេញចិត្ត

POSITION AVAILABLE
នៅមានកន្លែងធ្វើការទំនេរ

PACKING ការងារវេចខ្ចប់
WAREHOUSE ការងារក្នុងឃ្លាំង
MANUFACTURING ការងារផលិត
MACHINE OPERATORS ការងារបញ្ជាម៉ាស៊ីន
ASSEMBLY ការងារផ្គុំគ្រឿង
GENERAL LABOR ការងារពលកម្មទូទៅ

COME IN AND APPLY TODAY
សូមអញ្ជើញមកដាក់ពាក្យសុំធ្វើការថ្ងៃនេះ

"Missa Bay" ជាក្រុមហ៊ុននាំមុខគេខាងម្ហូបអាហារ និងបន្លែស្រស់ នៅ ស.រ.អា ឥឡូវនេះ កំពុងរកអ្នកធ្វើការ៤០នាក់ ដើម្បីវៀបចំម្ហូប មិនចាំបាច់មានបទពិសោធន៍ ឬចំណេះខាងភាសាអង់គ្លេស ធ្វើការក្នុងបរិយាកាសសីតុណ្ហភាព ៤០°F ស្ពាត ។ កំរៃផ្តើមពី ៨.៥ដុល្លារ ក្នុង១ម៉ោង កំរៃធ្វើលើសម៉ោង ១២.៧៥ ដុល្លារ ក្នុងមួយម៉ោង ធ្វើការលើស ៤០ ម៉ោង ក្នុងមួយអាទិត្យ ក្រុមហ៊ុនមានរថយន្តដឹកជញ្ជូនទៅកន្លែងធ្វើការ

យើងបានទុលពាក្យសុំធ្វើការនៅពីកន្លែងហើយគឺ :

CHINATOWN: 207 N. 9TH STREET. PHILADELPHIA, PA 19107
TEL: 215-829-0188 (MON-FRIDAY)
9:00-5:00 P.M.
215-880-2724 (Sat & Sunday)
SOUTH PHILLY: 529 WASHINGTON AVE., PHILADELPHIA, PA
សូមសួរកេ : ចាន់ សូម៉ាលី
TEL: 267-608-0742 / 215-462-3508 (MON-FRIDAY)
267-238 2388 (Sat& Sunday)
OnTime Staffing, LLC

HONG KONG
SUPERMARKET

FAMER´S BEST

$1.69/can

3 for $10

Newly Renovated.
Added new section .
Clean and Improved
management !
ទើបនឹងកែលំអរថ្មីឡើងវិញ
បន្ថែមផ្នែកលក់ថ្មីទៀត
ហាងស្អាត បើយបង្កើន
គុណភាពគ្រប់គ្រង
Weekly Sale
លក់ចុះថ្លៃរៀងរាល់សប្តាហ៍

$2.99/bag

$7.99

$2.99

$6.99/box

$1.29/can

$2.49/28oz

$2.49/bag

2 for $3

$4.99 / lb



$4.99

OPEN
7 DAY
8:00-9:00

571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-72801300 Fax: 215-728-1600

- ចំណាយ **$140**ដុល្លារ ទទួលបានអង្ករស្រូវសុ ២៥ ផោន
- ចំណាយ **$100**ដុល្លារ ទទួលបាននូវភេសជ្ជៈ ឬមីកញ្ចប់មួយប្រអប់(តម្លៃ **8.99**)
- ចំណាយ **$25** ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

ប្រធានអង្គការក្រុងខ្មែរ ថ្លែងទៅកាន់ភ្ញៀវដែលចូលរួម

ការបង្ហាញពីប្រពៃណីក្នុងការរៀប

ក្បួនសង្ក្រាន្តពិសិដ្ឋ

ការបង្ហួតបង្ហាញពីមរតកវប្បធម៌ខ្មែរ

ក្រុងខ្មែរ, ខ្មែរប៉ុស្ដិ៍ : ភ៉ានាថ

•••គណៈកម្មាធិការក្រុងខ្មែរ ឡុងប៊ិច បានរួមសហការជាមួយលោកចៅសង្កាត់ទី6 Dee Andrews កាលពីថ្ងៃទី6 ធ្នូ កន្លងទៅនេះនាំគ្នាធ្វើការតាំងពិព័រណ៍មរតកវប្បធម៌ សិល្បៈ និងស្ដីពីការរស់នៅពីជីវិត ប្រចាំថ្ងៃរបស់ជនជាតិខ្មែរ ។

ប្រធានអង្គការក្រុងខ្មែរអ្នកស្រី សិទ្ធា សាន បានមានប្រសាសន៍ថា ការតាំងពិព័រណ៍ស្ដីពីមរតកវប្បធម៌ គឺចង់បង្ហាញជូនភ្ញៀវពិសេសជនជាតិដទៃ ឱ្យយល់ដឹងពីរបៀបរបបរស់នៅជាមួយវប្បធម៌សំបូរបែបរបស់ជនជាតិខ្មែរ ។

នៅទីកន្លែងនៃការតាំងពិព័រណ៍មរតកវប្បធម៌នោះមានភ្ញៀវខ្មែរ និងបរទេសជាច្រើនរយនាក់ បាននាំគ្នាទៅទស្សនាក្នុងការស្វែងយល់ពីវប្បធម៌ខ្មែរ និងការកំសាន្តភ្នែកចំពោះសកម្មភាពនៃការលេងប្រគំនូវ រាំត្រុង រាំអប្សរា ឆៃយ៉ាំ ល្ខោនស្បែក ការជិះចោក ស៊ីកូ លេងយ៉ាងសប្បាយការបង្ហាញពីប្រពៃណីនៃការរៀបអាពាហ៍ពិពាហ៍ជាមួយសម្លៀកបំពាក់បែបបុរាណ ការបង្ហាញពីប្រពៃណីភ្លេងបុរាណខ្មែរ ។ ជាងគំនូរក៏បានបង្ហាញពីស្នាដៃគួររួបឱ្យភ្ញៀវមើលកំសាន្តជាមួយការពន្យល់បង្ហាញពីអក្សរសាស្ត្រខ្មែរពីម្ខាស់បណ្ណាល័យមាតុភូមិ និងពីអ្នកប្រវត្តិសាស្ត្រ លោក សន ជ័យសិទ្ធិ ជាដើម ។

អ្នកស្រី សិទ្ធា សាន និយាយថា ការតាំងពិព័រណ៍មរតកវប្បធម៌ខ្មែរយើងនេះបានធ្វើឱ្យភ្ញៀវបរទេសមានការចាប់អារម្មណ៍ និងយល់ដឹងពីតម្លៃនៃអរិយធម៌ ចំណាស់របស់ជនជាតិខ្មែរដែលមានមករាប់សតវត្សហើយ ។ នេះគឺជាកម្មវិធី ការតាំងពិព័រណ៍ជាលើកទី1 នៅលើទឹកដីសហគមន៍ខ្មែរ (ក្រុងខ្មែរ) នៅឡុងប៊ិច។

សន ជ័យសិទ្ធិ កំពុងបង្ហាញស៊ីកូដែលគេប្រើក្នុងការលេងល្បែងពីបុរាណ

ក្រុមរាំខ្មែរ

សាស្ត្រាចារ្យ សន ជ័យសិទ្ធិ មានប្រសាសន៍ថា ការពន្យល់បង្ហាញពីអក្សរសាស្ត្រខ្មែរធ្វើឱ្យភ្ញៀវបរទេសបានយល់ដឹងពីវប្បធម៌ និងពីជីវិតរស់នៅប្រចាំថ្ងៃរបស់ជនជាតិខ្មែរ រហូតដល់មានបរទេសរាប់រយនាក់ឱ្យយើងសរសេរឈ្មោះរបស់ពួកគេជាភាសាខ្មែរដើម្បីរក្សាទុកនូវឈ្មោះរបស់ពួកគេដែលយើងបានសរសេរឱ្យ ។ លោក ជ័យសិទ្ធិ បានថ្លែងថា ការតាំងពិព័រណ៍ស្ដីពីមរតកវប្បធម៌ខ្មែរនេះឡើង គឺផ្ដល់នូវសារៈសំខាន់ និងមានប្រយោជន៍ដល់តម្លៃជនជាតិខ្មែរដែលតែងតែមានវប្បធម៌រស់រវើក និងសំបូរបែប ។

គុជ សុជាតិ ម្ចាស់បណ្ណាល័យមាតុភូមិ ដែលផ្ដុំកនូវឯកសារស្បៃវ៉ែកៅ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ និងឯកសារទាក់ទងទៅនឹងវប្បធម៌ អរិយធម៌ បាននិយាយថា មានស្បៃវ៉ែកៅ DVD, CD និងឯកសារផ្សេងៗទៀត ដែលយើងបានបង្ហាញជូនដល់ភ្ញៀវបរទេសឱ្យយល់ជ្រាបពីអ្វីដែលទាក់ទងនឹងជីវិតខ្មែរ រស់នៅពីតំណរដូនតារហូតដល់សព្វថ្ងៃ ។

លោក មឿង សុន ប្រធានមូលនិធិទ្រទ្រង់អរិយធម៌ខ្មែរ ដែលកំពុងតែមានបេសកកម្មការងារនៅសហរដ្ឋអាមេរិកបានប្រាប់ "ខ្មែរប៉ុស្ដិ៍" ឱ្យដឹងថា រូបលោកវីកអាយ និងសប្បាយចិត្តនៅពេល ដែលឃើញបងប្អូននៅក្រៅប្រទេសដូចជាខ្មែរនៅទីក្រុងឡុងប៊ិច ដែលបានរៀបចំការតាំងពិព័រណ៍ស្ដីពីមរតកវប្បធម៌ខ្មែរ នេះជាការមើលឃើញពីចំណុចនៃការលើកតម្លៃពីនយោបាយប្រទេសជាតិខ្មែរ យើងតាមរយៈការផ្សព្វផ្សាយពីអរិយធម៌ខ្មែរមួយនេះ ។ ហើយក៏ធ្វើឱ្យខ្មែរយើងចំណេញខាងផ្នែកសេដ្ឋកិច្ច ដើម្បីរួមចំណែកក្នុងអភិវឌ្ឍន៍ប្រទេសជាតិក្នុងការកាត់បន្ថយភាពក្រីក្រប្រជាជន ។

លោក មឿង សុន បានបន្ដថា ការផ្សព្វផ្សាយពីឧស្សាហកម្មភ្ញាននៅផ្សេងនៃវិស័យទេសចរណ៍ដែលទាក់ទងទៅនឹងវប្បធម៌ខ្មែរ វានាំប្រយោជន៍ដល់ការទាក់ទាញភ្ញៀវទេសចរបរទេសឱ្យទៅទស្សនាប្រទេសកម្ពុជា ។

ទៅសង្កាត់ Dee Andrews និងក្រុមរំដែលជាខ្មែរ (រូបថតផ្ដល់ដោយអង្គការក្រុងខ្មែរ)

ក្រុមអ្នកទស្សនាមិនថាខ្មែរ ឬបរទេស បាននិយាយប្រាប់ខ្មែរប៉ុស្ដិ៍ ឱ្យដឹងថា ពួកគេស្នើឱ្យអ្នក រៀបចំកម្មវិធីគួរតែមានកម្មវិធីការតាំងពិព័រណ៍ឬល្បែងកំសាន្តប្រពៃណីខ្មែរដែលយ៉ាងហោចណាស់ក៏មួយឆ្នាំម្ដងដែរ ដើម្បីបង្ហាញពីអត្តសញ្ញាណជាតិខ្មែរវប្បធម៌ខ្មែរ ឆ្ពោះទៅរកការផ្សព្វផ្សាយបន្ថែមនូវភាពទូលំទូលាយនៅលើកឆាកអន្តរជាតិ ពីតម្លៃខ្មែរនោះ ។

ប្រទេសកម្ពុជាស្ទើរតែរលត់រលាយនូវវប្បធម៌ទាំងស្រុងក្នុងរបបខ្មៅងងឹតនៃវាលពិឃាតខ្មែរក្រហមនាឆ្នាំ 1975 ដែលអ្នកចេះដឹង អ្នកប្រាជ្ញ បញ្ញវន្ត និស្សិត គ្រូវិគេសម្លាប់ចោល ពលរដ្ឋទូទាំងនគរមិនឱ្យ រៀនសូត្រ ចេះអ ក្សរឯកសារ វប្បធម៌ ប្រវត្តិសាស្ត្រ អក្សរសាស្ត្រត្រូវបំផ្លាញចោលទាំងស្រុង និងផ្ដែកសាសនាត្រូវបំបាត់ចោលមិនឱ្យមានអ្នកជំនឿ ភ្ញាន ព្រះសង្ឃ ភ្ញានវត្តអារាម ក្រៅតែពីការបង្ខំមនុស្សឱ្យ ធ្វើការហួសកម្លាំង បង្អត់អាហារនិងការធ្វើទារុណកម្មសម្លាប់មនុស្សយ៉ាងឃោរឃៅរហូតមានខ្មែរស្លូតត្រង់ជិត2លាននាក់ ត្រូវបានស្លាប់បាត់បង់ជីវិត ។

ស្របនឹងរបបខ្មៅងងឹតមួយដែលដឹកនាំដោយពូកទមិឡឥតសាសនារបស់ ប៉ុល ពត នោះប្រទេសកម្ពុជាបានប្រែក្លាយមករកស្ថានការណ៍ដើមឡើងវិញ ។ ហើយកម្ពុជាក៏បានប្រែក្លាយជាប្រទេសមួយ ដែលមានសម្បត្តិដ៏មានតម្លៃមហាសាល និងល្បីល្បាញរន្ទឺនៅលើពិភពលោកនៃអច្ឆរិយពិភព លោក គឺប្រាង្គប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ រហាំល្ខោនស្បែក និងវត្ថុបុរាណ តំបន់បុរាណផ្សេងៗទៀតត្រូវបានទទួលស្គាល់និងការដាក់ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកទៀតផង ។

Danny's Café

Foods & Hoagies

1. Beef Stew Serve with Bread.....នំប៉័ងខគោ
2. Curry Chicken Serve with Bread.....នំប៉័ងការីសាច់មាន់
3. Curry Beef Saramann Serve with Bread.....នំប៉័ងសាច់គោ ខការីសារាមាន់
4. Meatball Soup Serve with Bread .....ស៊ុបប្រហិតជាមួយនំប៉័ង
5. Mi Siam .....មីសៀម

1730 Snyder Ave, Philadelphia, PA 19145 / Mon – Fri: 7am – 7pm Saturday: 9 am – 8 pm / Sunday : CLOSED
Tel: 215.467.4082 Fax: 215.467.4642 / Thank You, Please come again !

ប្រតិទិនប្រវត្តិសាស្ត្រ ខ្មែរប៉ុស្តិ៍ គ.ស 2010

ទូរស័ព្ទលេខ 267-254-8758 E-mail: khmerpostusa@gmail.com

មករា 1 JANUARY CALENDAR

Holiday Summary	ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
					1 ១រោច ខែបុស្ស	2 ២រោច ខែបុស្ស
3 ៣រោច ខែបុស្ស	4 ៤រោច ខែបុស្ស	5 ៥រោច ខែបុស្ស	6 ៦រោច ខែបុស្ស	7 ៧រោច ខែបុស្ស	8 ខ ៨រោច ខែបុស្ស	9 ៩រោច ខែបុស្ស
10 ១០រោច ខែបុស្ស	11 ១១រោច ខែបុស្ស	12 ១២រោច ខែបុស្ស	13 ១៣រោច ខែបុស្ស	14 ១៤រោច ខែបុស្ស	15 ខ ១៥រោច ខែបុស្ស	16 ១កើត ខែមាឃ
17 ២កើត ខែមាឃ	18 ៣កើត ខែមាឃ	19 ៤កើត ខែមាឃ	20 ៥កើត ខែមាឃ	21 ៦កើត ខែមាឃ	22 ៧កើត ខែមាឃ	23 ខ ៨កើត ខែមាឃ
24/31 ៩កើត/១រោច ខែមាឃ	25 ១០កើត ខែមាឃ	26 ១១កើត ខែមាឃ	27 ១២កើត ខែមាឃ	28 ១៣កើត ខែមាឃ	29 ១៤កើត ខែមាឃ	30 ខ ១៥កើត ខែមាឃ

កុម្ភៈ 2 FEBRUARY CALENDAR

Holiday Summary	ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
	1 ២រោច ខែមាឃ	2 ៣រោច ខែមាឃ	3 ៤រោច ខែមាឃ	4 ៥រោច ខែមាឃ	5 ៦រោច ខែមាឃ	6 ៧រោច ខែមាឃ
ខ 7 ៨រោច ខែមាឃ	8 ៩រោច ខែមាឃ	9 ១០រោច ខែមាឃ	10 ១១រោច ខែមាឃ	11 ១២រោច ខែមាឃ	12 ១៣រោច ខែមាឃ	ខ 13 ១៤រោច ខែមាឃ
14 ១៥រោច ខែមាឃ	15 ១កើត ខែផល្គុន	16 ២កើត ខែផល្គុន	17 ៣កើត ខែផល្គុន	18 ៤កើត ខែផល្គុន	19 ៥កើត ខែផល្គុន	20 ៦កើត ខែផល្គុន
ខ 21 ៧កើត ខែផល្គុន	22 ៨កើត ខែផល្គុន	23 ៩កើត ខែផល្គុន	24 ១០កើត ខែផល្គុន	25 ១១កើត ខែផល្គុន	26 ១២កើត ខែផល្គុន	27 ១៣កើត ខែផល្គុន
ខ 28 ១៤កើត ខែផល្គុន						

មិនា 3 MARCH CALENDAR

Holiday Summary	ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
	1 ១រោច ខែផល្គុន	2 ២រោច ខែផល្គុន	3 ៣រោច ខែផល្គុន	4 ៤រោច ខែផល្គុន	5 ៥រោច ខែផល្គុន	6 ៦រោច ខែផល្គុន
7 ៧រោច ខែផល្គុន	ខ 8 ៨រោច ខែផល្គុន	9 ៩រោច ខែផល្គុន	10 ១០រោច ខែផល្គុន	11 ១១រោច ខែផល្គុន	12 ១២រោច ខែផល្គុន	13 ១៣រោច ខែផល្គុន
14 ១៤រោច ខែផល្គុន	ខ 15 ១៥រោច ខែផល្គុន	16 ១កើត ខែចេត្រ	17 ២កើត ខែចេត្រ	18 ៣កើត ខែចេត្រ	19 ៤កើត ខែចេត្រ	20 ៥កើត ខែចេត្រ
21 ៦កើត ខែចេត្រ	22 ៧កើត ខែចេត្រ	ខ 23 ៨កើត ខែចេត្រ	24 ៩កើត ខែចេត្រ	25 ១០កើត ខែចេត្រ	26 ១១កើត ខែចេត្រ	27 ១២កើត ខែចេត្រ
28 ១៣កើត ខែចេត្រ	29 ១៤កើត ខែចេត្រ	ខ 30 ១៥កើត ខែចេត្រ	31 ១រោច ខែចេត្រ			

លំដាប់កាលប្រវត្តិសាស្ត្រខ្មែរ

សម័យខ្មែរមេន ឆ្នាំ-៤000 → ផ្សព្វផ្សាយតទ្ធិពលកណ្តាល ឆ្នាំ-១00មុនគ.ស → +100 ឆ្នាំ ក្រោយគ.ស → នគរហ្វូណន ឬនគរភ្នំ +200 → ចេនឡា ឆ្នាំ+500 → សម័យកសាង +800 → សម័យអង្គរ

មេសា 4 APRIL CALENDAR

Holiday Summary	ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
				1 ២រោច ខែចេត្រ	2 ៣រោច ខែចេត្រ	3 ៤រោច ខែចេត្រ
4 ៥រោច ខែចេត្រ	5 ៦រោច ខែចេត្រ	6 ៧រោច ខែចេត្រ	ខ 7 ៨រោច ខែចេត្រ	8 ៩រោច ខែចេត្រ	9 ១០រោច ខែចេត្រ	10 ១១រោច ខែចេត្រ
11 ១២រោច ខែចេត្រ	12 ១៣រោច ខែចេត្រ	ខ 13 ១៤រោច ខែចេត្រ	14 ១កើត ខែពិសាខ	15 ២កើត ខែពិសាខ	16 ៣កើត ខែពិសាខ	17 ៤កើត ខែពិសាខ
18 ៥កើត ខែពិសាខ	19 ៦កើត ខែពិសាខ	20 ៧កើត ខែពិសាខ	ខ 21 ៨កើត ខែពិសាខ	22 ៩កើត ខែពិសាខ	23 ១០កើត ខែពិសាខ	24 ១១កើត ខែពិសាខ
25 ១២កើត ខែពិសាខ	26 ១៣កើត ខែពិសាខ	27 ១៤កើត ខែពិសាខ	ខ 28 ១៥កើត ខែពិសាខ	29 ១រោច ខែពិសាខ	30 ២រោច ខែពិសាខ	

ឧសភា 5 MAY CALENDAR

Holiday Summary	ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
						1 ៣រោច ខែពិសាខ
2 ៤រោច ខែពិសាខ	3 ៥រោច ខែពិសាខ	4 ៦រោច ខែពិសាខ	5 ៧រោច ខែពិសាខ	ខ 6 ៨រោច ខែពិសាខ	7 ៩រោច ខែពិសាខ	8 ១០រោច ខែពិសាខ
9 ១១រោច ខែពិសាខ	10 ១២រោច ខែពិសាខ	11 ១៣រោច ខែពិសាខ	12 ១៤រោច ខែពិសាខ	ខ 13 ១៥រោច ខែពិសាខ	14 ១កើត ខែជេស្ឋ	15 ២កើត ខែជេស្ឋ
16 ៣កើត ខែជេស្ឋ	17 ៤កើត ខែជេស្ឋ	18 ៥កើត ខែជេស្ឋ	19 ៦កើត ខែជេស្ឋ	20 ៧កើត ខែជេស្ឋ	ខ 21 ៨កើត ខែជេស្ឋ	22 ៩កើត ខែជេស្ឋ
23/30 ១០កើត/២រោច ខែជេស្ឋ	24/31 ១១កើត/៣រោច ខែជេស្ឋ	25 ១២កើត ខែជេស្ឋ	26 ១៣កើត ខែជេស្ឋ	27 ១៤កើត ខែជេស្ឋ	ខ 28 ១៥កើត ខែជេស្ឋ	29 ១រោច ខែជេស្ឋ

មិថុនា 6 JUNE CALENDAR

Holiday Summary	ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
		1 ៤រោច ខែជេស្ឋ	2 ៥រោច ខែជេស្ឋ	3 ៦រោច ខែជេស្ឋ	4 ៧រោច ខែជេស្ឋ	ខ 5 ៨រោច ខែជេស្ឋ
6 ៩រោច ខែជេស្ឋ	7 ១០រោច ខែជេស្ឋ	8 ១១រោច ខែជេស្ឋ	9 ១២រោច ខែជេស្ឋ	10 ១៣រោច ខែជេស្ឋ	ខ 11 ១៤រោច ខែជេស្ឋ	12 ១កើត ខែបឋមាសាឍ
13 ២កើត ខែបឋមាសាឍ	14 ៣កើត ខែបឋមាសាឍ	15 ៤កើត ខែបឋមាសាឍ	16 ៥កើត ខែបឋមាសាឍ	17 ៦កើត ខែបឋមាសាឍ	18 ៧កើត ខែបឋមាសាឍ	ខ 19 ៨កើត ខែបឋមាសាឍ
20 ៩កើត ខែបឋមាសាឍ	21 ១០កើត ខែបឋមាសាឍ	22 ១១កើត ខែបឋមាសាឍ	23 ១២កើត ខែបឋមាសាឍ	24 ១៣កើត ខែបឋមាសាឍ	25 ១៤កើត ខែបឋមាសាឍ	ខ 26 ១៥កើត ខែបឋមាសាឍ
27 ១រោច ខែបឋមាសាឍ	28 ២រោច ខែបឋមាសាឍ	29 ៣រោច ខែបឋមាសាឍ	30 ៤រោច ខែបឋមាសាឍ			

លំដាប់កាលប្រវត្តិសាស្ត្រខ្មែរ(ត)

កសាង ឆ្នាំ +900 → តំណាក់កាលរុងរឿង សម័យអង្គរ → រុងរឿងបំផុត សិទ្ធិដែលតំណាងព្រះឥសូរ ឆ្នាំ +1100 → ដំណាក់កាលធ្លាក់ចុះ ព្រះកសត្រះឆានជ័យវរ្ម័នទី៧ ឆ្នាំ .1200 → បោះបង់អង្គរ ឆ្នាំ +1400 សម័យអង្គរ → ឆ្នាំ +1430



FOR ADVERTISING , CALL (267) 253-3947

ប្រតិទិនប្រវត្តិសាស្ត្រ ខ្មែរប៉ុស្តិ៍ គ.ស 2010

ទូរស័ព្ទលេខ 267-254-8758 E-mail: khmerpostusa@gmail.com

កក្កដា 7 JULY CALENDAR

ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
			1	2	3
4	5	6	7	8	9	10
11	12	13	14	15	16	17
18	19	20	21	22	23	24
25	26	27	28	29	30	31

សីហា 8 AUGUST CALENDAR

ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
1	2	3	4	5	6	7
8	9	10	11	12	13	14
15	16	17	18	19	20	21
22	23	24	25	26	27	28
29	30	31				

កញ្ញា 9 SEPTEMBER CALENDAR

ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
		1	2	3	4
5	6	7	8	9	10	11
12	13	14	15	16	17	18
19	20	21	22	23	24	25
26	27	28	29	30		

លំដាប់កាលប្រវត្តិសាស្ត្រខ្មែរ (ក)

បោះបង់អង្គរ → សម័យចតុមុខ ឆ្នាំ +1500 → សម័យលង្វែក ឆ្នាំ+1600 → សម័យឧត្តុង្គ ឆ្នាំ+1800 → សម័យបារាំង ឆ្នាំ+1860

តុលា 10 OCTOBER CALENDAR

ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
				1	2
3	4	5	6	7	8	9
10	11	12	13	14	15	16
17	18	19	20	21	22	23
24/31	25	26	27	28	29	30

វិច្ឆិកា 11 NOVEMBER CALENDAR

ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
	1	2	3	4	5	6
7	8	9	10	11	12	13
14	15	16	17	18	19	20
21	22	23	24	25	26	27
28	29	30				

ធ្នូ 12 DECEMBER CALENDAR

ច័ន្ទ Monday	អង្គារ Tuesday	ពុធ Wednesday	ព្រហ. Thursday	សុក្រ Friday	សៅរ៍ Saturday
		1	2	3	4
5	6	7	8	9	10	11
12	13	14	15	16	17	18
19	20	21	22	23	24	25
26	27	28	29	30	31	

លំដាប់កាលប្រវត្តិសាស្ត្រខ្មែរ (ត និង ច)

បារាំង → សម័យសង្គមរាស្ត្រនិយម +1954 ឆ្នាំ +1970 → សម័យសាធារណរដ្ឋ +1975 → សម័យកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ +1979 → សម័យរដ្ឋកម្ពុជា → សម័យព្រះរាជាណាចក្រកម្ពុជា ឆ្នាំ+1993



ចង់ផ្សាយពាណិជ្ជកម្មនៅក្នុងប្រតិទិនប្រវត្តិសាស្ត្រ ប៉ុស្តិ៍ខ្មែរ ដែលមានចែកជូនប្រជាពលរដ្ឋ ក្នុងរដ្ឋ Philadelphia ជាង ៥ម៉ឺនច្បាប់ សូមទាក់ទងមកកាន់ FOR ADVERTISING , CALL (267) 253-3947

ឌី ឃែមបូឌា ដេលី
The Cambodia Daily
ជំណឹងប្រៃសំរួលពីភាសាអង់គ្លេស អត្ថបទបានអនុញ្ញាតិឱ្យធ្វើការចុះផ្សាយដោយ ឌី ឃែមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី១៨ ខែធ្នូ ឆ្នាំ២០០៩

Plight of Sex Workers Focus of Int'l Day

By Kuch Naren
THE CAMBODIA DAILY

Around 200 prostitutes, transgendered people and men who have sex with men gathered in Phnom Penh at the Russei Keo district offices of the NGO Women's Network for Unity yesterday to mark the first Cambodian celebration of the International Day to End Violence Against Sex Workers.

The group asked an audience, which included local authorities and police from six Phnom Penh districts, to end the arrests and intimidation of sex workers nationwide and also called on the National Assembly and other relevant government bodies to create laws protecting sex workers from arrest and violence.

"Please examine law-enforcement policies on anti-human trafficking and the sex trade, because they have created the potential for physical and sexual abuse by law enforcement [officials]," said Pek Sokchea, a member of the WNU steering committee, in a speech at the event.

She added that arrests should be made to help victims of true human trafficking, but that adults working voluntarily as prostitutes should not be arrested for plying their trade as a means to make a modest living for their families.

"Some women are the key pillars in earning income to feed their parents and children," Ms Sokchea said. "If they are caught and detained in shelters or forced to get vocational training, who will be responsible for the children and parents that need food to eat?"

Continued on page 16

អ្នករកស៊ីផ្លូវភេទរាប់រយនាក់ ប្រារព្ធទិវាអន្តរជាតិបញ្ចប់អំពើហិង្សា

ដោយ : គុច ណារ៉ែន
The Cambodia dailly

● ស្រីពេស្យាមនុស្សខ្ទើយ និងមនុស្សប្រុសរួមភេទជាមួយនឹងប្រុសដូចគ្នាប្រមាណជា ២០០ នាក់ បានប្រមូលផ្តុំគ្នាក្នុងទីក្រុងភ្នំពេញនៅឯការិយាល័យអង្គការក្រៅរដ្ឋាភិបាលបណ្តាញស្ត្រីរួបរួមគ្នា (WNU) ក្នុងខណ្ឌឫស្សីកែវ កាលពីម្សិលមិញដើម្បីប្រារព្ធទិវាអន្តរជាតិ ដើម្បីបញ្ចប់អំពើហិង្សាប្រឆាំងអ្នករកស៊ីផ្លូវភេទនៅក្នុងប្រទេសកម្ពុជាលើកទី១ ។

ក្រុមនេះ បានសុំអ្នកចូលរួមស្តាប់ដែលរាប់បញ្ចូលទាំងអាជ្ញាធរ និងប៉ូលិសមូលដ្ឋានមកពីខណ្ឌចំនួន៦ ក្នុងក្រុងភ្នំពេញឱ្យបញ្ចប់ការចាប់ខ្លួន និងការបំភិតបំភ័យអ្នករកស៊ីផ្លូវភេទទូទាំងប្រទេស ហើយក៏បានអំពាវនាវដែងដែរដល់រដ្ឋសភា និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធផ្សេងទៀតឱ្យបង្កើតច្បាប់ការពារក្រុមអ្នករកស៊ីផ្លូវភេទមិនឱ្យមានការចាប់ខ្លួន និងប្រើអំពើហិង្សាឡើយ ។

យោងតាម WNUឱ្យដឹងថា សារ និងរូបថតរបស់អ្នករកស៊ីផ្លូវភេទ ដែលត្រូវបានរំលោភបំពានព្យួរនៅតាមជញ្ជាំងនៃការិយាល័យ WNU និងមានការដាក់បញ្ចាំងស្លាយដែលពណ៌នាអំពីអ្នករកស៊ីផ្លូវភេទជាច្រើនដែលរងរបួសនៅលើផ្ទៃមុខ ខ្នង និងរាងកាយរបស់ពួកគេដែលតាមចោទថា ដោយសារអំពើឃោរឃៅរបស់ប៉ូលិស ។

លោកស្រី ពេក សុខជា សមាជិកគណៈកម្មាធិការនាយក WNU បានថ្លែងក្នុងសន្ទរកថាមួយនៅឯព្រឹត្តការណ៍នេះថា "សូមពិនិត្យមើលគោលនយោបាយអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស តទៅទំព័រទី ១៨

ការិយាល័យវេជ្ជសាស្ត្រ

5746 Rising Sun Avenue. Philadelphia, Pa 19120
Phone: (215)904-6891 Fax: (215) 745-2290

DR. TRUONG H. NGUYEN, M.S., D.O., P.C

FAMILY MEDICINE – INTERNAL MEDICINE – OSTEOPATHIC MANIPULATIVE THERAPY

វេជ្ជបណ្ឌិតជំនាញខាងព្យាបាលជម្ងឺចឹកនោម_ផ្តាសាយ_ក្អក_ពិនិត្យសុខភាពស្ត្រី (GYN) _ពិនិត្យតម្រងនោម_ប្រព័ន្ធរំលាយអាហារ...

* ឆែកពិនិត្យសុខភាពជាប្រចាំ និងព្យាបាលជម្ងឺស្បែក....ឈឺក្បាលប្រកាំង, ឈឺសន្លាក់ដៃជើង បញ្ហាក់សុខភាពសម្រាប់អាពាហ៍ពិពាហ៍, សម្រាប់ធ្វើដំណើរ និង សម្រាប់សាលារៀន
* **ជាពិសេស : ទទួលព្យាបាលអ្នកគ្រោះថ្នាក់មានមុខរបួស ឬរអិលដួលនៅកន្លែងធ្វើការ យើងណែនាំផ្តល់មេធាវីដែលមានបទពិសោធន៍ជាង ២០ ឆ្នាំ និងអ្នកបកប្រែភាសាជំនាញ មានខ្មែរ-ចិន-វៀតណាម ជូនដោយឥតគិតថ្លៃ បើលោកអ្នកត្រូវការ :**
* ធានាថា យើងធ្វើការបានលទ្ធផលឆាប់រហ័ស-លើសពីនេះ យើងរីករាយនឹងជួយដល់ភ្ញៀវណាដែលមិនចេះនិយាយអង់គ្លេស ហើយចង់កំណត់ពេលទៅមន្ទីរពេទ្យ ឬចង់ប្តូរក្រុមហ៊ុនធានាសុខភាព (Health Insurance)
* **យើងទទួល មេឌីកេដ,មេឌីឃែ , និង អ៊ុនស៊ូរិន ស្ទើរតែទាំងអស់ និងគិតថ្លៃទាបជូនអ្នកដែលមិនមាន អ៊ុនស៊ូរិន ទៀតផង ។**

ការិយាល័យបើកទ្វារ :៣
ថ្ងៃ ច័ន្ទ -អង្គារ-ពុធ- និង សុក្រ
ពីម៉ោង ៩ព្រឹកដល់១រសៀល
និងពីម៉ោង ៣ ដល់ ៧ ល្ងាច
បិទទ្វារ : ថ្ងៃ សៅរ៍ និងថ្ងៃអាទិត្យ និងព្រហស្បត្តិ៍

ខ្មែរមានពូជ

•••វាគ្មិនបួនរូប បានរៀបចំសិក្ខាសាលាមួយ នៅវត្តពោធិវង្ស នៃប្រទេសបារាំង ដើម្បីសិក្សារកបុរសគល់ ដែលចេះតែនាំឱ្យខ្មែរ ឯនភាពផ្នែកស្មារតីតាំងពីបន្ទាប់សម័យអង្គរមក ។ ចំណោមអ្នកទាំងបួននោះ ក៏មានព្រះសង្ឃមួយអង្គផងដែរ ព្រះនាម ជិន ភេន, លោកវេជ្ជបណ្ឌិត ស៊ុយ សៀងហេង, លោក ឌី ការ៉ែត និង លោក ចាយ សេរីវុឌ្ឍ កាលពីថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៩ ។ វត្តពោធិ៍វង្ស 101 BOULEVARD DELA REPUBLIQUE 77420 CHAPS SUN MARNE-FRANCE ។ ខ្មែរប៉ុស្ត៍ បានលើកយកប្រយោគជាសេចក្តីរាយការណ៍របស់អ្នកទាំងបួនមកអានជាសណ្តាប់ ដោយយល់ថា ភាពនិនខ្សោយនៃស្មារតីខ្មែរ នាពេលនេះ នៅតែជាកង្វល់របស់សាធារណជនស្មើគ្រប់ៗគ្នា ។ សូមអញ្ជើញអាននូវប្រយោគរបស់អ្នកទាំងបួន ដែលធ្វើវិភាគជូនសហគមន៍ខ្មែរជាច្រើននៅប្រទេសបារាំងដូចតទៅ :

លោក ស៊ុយ សាងហេង
នមតុ វតនវណ្ណស្ស

ពាក្យថា ពូជ គឺតំណជាតិ កំណើត ឬវង្សត្រកូលរបស់មនុស្ស សត្វ ឬ រុក្ខជាតិ ។ ដូចនេះ មនុស្ស សត្វ រុក្ខជាតិ តែកើតមកហើយ ត្រូវមានពូជទាំងអស់ ។ តែខ្មែរមានទម្លាប់ប្រើថា មនុស្សមានពូជ គឺមនុស្សមានការអប់រំល្អ ។ លក្ខណៈខ្ពង់ខ្ពស់ ហើយដែលគួររាប់ថាជារបស់ខ្មែរយើងពិតៗ មាន ២ ពួក :

ក. លក្ខណៈនៅក្នុងខ្លួន និង **ខ. លក្ខណៈនៅក្រៅខ្លួន** ។

ក. លក្ខណៈនៅក្នុងខ្លួន ដែលមានពីកំណើតមក

តាមវិទ្យាសាស្ត្រ មនុស្សនៅលើផែនដីទាំងអស់មានពូជតែមួយទេ ។ អ្នកប្រាជ្ញខាងវត្ថុបុរាណ បានរកឃើញថា កាលពី ៤០.000[9] ឆ្នាំមុន មានមនុស្សដែលប្រកបដោយចរិតលក្ខណៈដូចយើងសព្វថ្ងៃ ១ ក្រុម បានរួចផុតពីស្ពាប់រង្គាល នៅក្នុងទ្វីបអាហ្វ្រិក ក្រុងប្រទេសបុតស្វាណា ណាមីប៊ី

[9]-៤០.000 ឆ្នាំមុន បន្ទាប់ពីមហាភ្នំភ្លើងនៅ ប៊ិកនេអូ (ឥណ្ឌូនេស៊ី) ភ្លើងឆេះផែនដី ផ្សែងបាំងព្រះអាទិត្យ ជីវិតនៅលើដីស្ងាប់ស្ងើរទាំងអស់ ។ ដំបូងដោយភ្លើងឆេះគ្មានសល់អ្វីសមុទ្រីរឹង បន្ទាប់មកដោយគ្មានធ្លីថ្ងៃ អាកាសត្រជាក់ ។ ក្នុងលោកទាំងមូល ពូជមនុស្ស១ក្រុម មិនដល់ ១.000 នាក់ទេ ដែលរួចជីវិតពីមហន្តរាយនេះ គឺជនដែលនៅឆ្ងាយពីភ្នំភ្លើង ក្នុងទ្វីបអាហ្វ្រិក ។ ពូជផ្សេង១ទៀត ស្ងាប់គ្មានសល់ ។ គេសន្និដ្ឋានថា សត្វដែលមានសណ្ឋានជាមនុស្សមានសតិអារម្មណ៍ស្រដៀងមនុស្ស តាំងតែពី ១៤០.000 ឆ្នាំ មកម្ល៉េះ ។ មានពូជជាច្រើន។

និង អាហ្វ្រិកខាងត្បូង ។ ពួកមនុស្សដើម្បីនេះ បែកកូនបែកចៅ ក៏សាយភាយពេញពិភពលោក រហូតដល់សព្វថ្ងៃនេះ ។ ដោយឡែកអ្នកប្រាជ្ញខាងលោហិតវិជ្ជា បានសង្កេតឃើញថា ពពួកមនុស្សទាំងនោះ បន្ទាប់ពីបានឆ្លងកាត់ទ្វីប កាត់មហាសាគរមក អ្នកខ្លះក៏រស់នៅក្នុងតំបន់ផ្សេង១ ក្នុងតំបន់នីមួយ១ មនុស្សមានការប្រែប្រួល : មាឌធំ ធាត់ ស្គម សស្លាំង ខ្មៅ សម្បុរសណ្តែកបាយ តែរចនាសម្ព័ន្ធឈាមគេនៅតែដដែលគ្មានដូរទេ ។ តែក្រោយមក ចរិត លក្ខណៈឈាមក្នុងក្រុមមនុស្សខ្លះមានដុះខ្លែងប្លែកបន្តិច ឯកូនចៅសុទ្ធតែទទួលលក្ខណៈឈាមជាមរតកពីមាតាបិតា ដូនតារហូតមកមិនដាច់ ។ នេះសឱ្យ ឃើញថា ពូជមនុស្សមានតែមួយគត់ ។

លោហិតវិជ្ជា វប្បធម៌ និងជាតិសាសន៍

លោហិតវិជ្ជា[10] និងវប្បធម៌ មានការទាក់ទង គ្នា គេចាប់ទទួលស្គាល់រឿងនេះ តាំងតែពីពេលដែលផ្តើមស្រាវជ្រាវរកជំពូកឈាមតាមភូមិសាស្ត្រជាលើកដំបូង ។ ដោយហេតុនេះ ទើបពួកលោហិតសាស្ត្របានរកឃើញជាតិ ហេមោគ្លោប៊ីន-អ៊ី Hémoglobine-E(Hb-E) នៅអាស៊ីអគ្នេយ៍ ក្នុងឈាមនៃជនជាតិខ្មែរ ។ រីឯអ្នកប្រាជ្ញខាងបុរាណវត្ថុវិញ ក៏បានរកឃើញគំនរថ្មនៃប្រាសាទបាក់បែក និងប្រាសាទជំនាន់អង្គរនៅលើភូមិភាគដដែលនៅដែរ ។ គឺថាបើមានប្រាសាទជំនាន់អង្គរនៅត្រង់ណា

(តទៅលេខក្រោយ)



ដោយ : ឌី ការ៉ែត

ខ្មែរមានពូជ គឺខ្មែរដែលកើតមកបានទទួលការអប់រំក្នុងគំនិតស្មារតី និងទំនៀមទម្លាប់ល្អនៃប្រជាជនខ្មែរ ។

ការស្រាវជ្រាវជាបន្ថែមថ្មីៗ ក្នុងប្រវត្តិសាស្ត្របានបង្ហាញថា ប្រជាជនខ្មែរ (និងប្រជាជន "មន") មានពូជពង្សបន្តពីប្រជាជនមួយ ហៅថា "មុនឌុះ" (Monda) ដែលជាប្រជាជនរស់នៅប្រទេសឥណ្ឌាមុនគេបំផុត កាលពីជាង ៣0.000 ឆ្នាំ មុនគ្រិស្តសករាជ (គ.ស.) ។ ដោយមិនព្រមទទួលរងអំណាចនៃពួកឈ្លានពានបរទេសជាបន្តបន្ទាប់ ចាប់ពីម៉ឺនឆ្នាំ ១0.000 មុន គ.ស. ប្រជាជនខ្មែរ បាននាំគ្នាចេញបីប្រទេសឥណ្ឌាបន្តិចម្តងៗ ហើយមកតាំងទីលំនៅនៅលើទឹកដីខ្លួនថ្មីសព្វថ្ងៃ ពីម៉ឺនឆ្នាំ ៦.000 មុន គ.ស.។ ពួក "មម" (Mom) ហៅថា "មន" (Mon) ដែលជាប់ខ្សែស្រឡាយនឹងខ្មែរ បានមកដល់ភូមា នៅម៉ឺនឆ្នាំ ៣.000 មុន គ.ស. ហេតុនេះ ជនជាតិខ្មែរ បានមករស់នៅលើទឹកដីសព្វថ្ងៃមុន ពួកសៀម ពួកឡាវ ពួកយួន ពួកចាម ចំនួនរាប់ពាន់ឆ្នាំ ដោយមានភាសាមានវប្បធម៌ មានសាសនា មានចំណេះវិជ្ជារបស់ខ្លួនផ្ទាល់ ហើយបានសាងសង់ប្រទេសខ្លួន ហៅថា "ស្រុកខ្មែរ" យ៉ាងមាំមួនជាស្រេច ។ លុះចាប់ពីដើមឆ្នាំគ្រិស្តសតវត្សទី១ ទើបខ្មែរមានការទាក់ទងជាថ្មីជាមួយនឹងពួកជនជាតិឥណ្ឌា ដែលមានឥទ្ធិពលមកនៅដល់ប្រទេសម៉ាឡេ នាពេលនោះ ។

នៅក្នុងប្រវត្តិសាស្ត្រខ្មែរសព្វថ្ងៃ យើងបានដឹងខ្លះៗ តែអំពីសម័យ ហ៊ិណន (នគរភ្នំ) សម័យចិនឡាសម័យអង្គរ ឬ កម្ពុជា ។ ប៉ុន្តែ នៅមុនសម័យ ហ៊ិណន "ស្រុកខ្មែរ" ជារដ្ឋខ្លាំងពូកែមួយទៅហើយ ដែលគោរពលទ្ធិពិសេសមួយហៅថា "មតេយ្យកា" (មេ ម្តាយ ឬ ស្រួ ជាធំ ជាអ្នកដឹកនាំ - Le matriarcat) និងកាន់សាសនាមួយ ដែលគោរពបូជា "មេ បា" "នាងគង្គីង ព្រះធរណី និងព្រលឹងក្រពើ" "អ្នកតា" ជាអាថ៌ ។ ជនជាតិខ្មែរ បានគោរពបូជាគុណបារមីទាំងនេះ នៅគ្រប់សម័យ ជាបន្តបន្ទាប់រហូត មកដល់សព្វថ្ងៃ ។ នេះសឱ្យឃើញថា រហូតមកដល់សព្វថ្ងៃ ប្រជាជនខ្មែរជា "ពូជ" តែមួយជានិច្ច ។

ទេពកោសល្យនៃប្រជាជនខ្មែរ

នៅក្នុងអតីតកាល គំនិតស្មារតី និងចំណេះវិជ្ជា មិនមែនបានកើតឡើង ក្នុងរយៈតែ ២0-៣0ឆ្នាំ ឬ ១00 ឆ្នាំទេ ។ ប្រទេសឥណ្ឌា ឬចិន ដែលមានអារ្យធម៌ខ្ពស់ហើយ នៅពេលនោះ ក៏មិនដែលបានមកគ្រប់គ្រង ឬ ដឹកនាំប្រជាជនខ្មែរទេ ។ តែប្រជាជនមានទេពកោសល្យខ្ពស់ ដោយមានបង្កើតសម្រាប់ជាតិសាសន៍ខ្លួនឯង នូវប្រព័ន្ធមួយដឹកនាំសង្គម និងប្រទេស (គឺរបបមតេយ្យកា) សាសនាមួយរបស់ខ្លួន (មេ-បា និងព្រះធម្មជាតិ) តួអក្សរ និងតួលេខមួយចំនួន (ដែលជាសញ្ញាផ្ទុំគ្នា រវាងព្យញ្ជនៈ និង ស្រៈ ដើម្បីបង្កើតជាពាក្យ គឺមិនមែនជាសញ្ញារូបភាពផ្ទុំគ្នាទេ) និង បច្ចេកទេសធ្វើស្រែ-ចំការ ការនេសាទ ការងារលោហធាតុ (ដែកស្ពាន់ ទង់ដែង មាស ប្រាក់...) ។ **(តទៅលេខក្រោយ)**

ចាយ សិរីវុឌ្ឍ

(ឬលក្ខណៈ នៃជនជាតិខ្មែរ)

ពាក្យថា "ខ្មែរមានពូជ" គឺខ្មែរជាអ្នកបានទទួលកេរមរតកដំណែលពី ជីដូន ជីតា និងមានអារ្យធម៌របស់ជនជាតិខ្លួនផ្ទាល់ ។ ក្នុងសម័យបច្ចុប្បន្ននេះ តម្លៃប្រពៃណីរបស់ប្រជាជនខ្មែរ ហាក់ដូចជាមានតែនៅក្នុងទីវត្តអារ៉ាមប៉ុណ្ណោះ ។ ដោយហេតុថា ព្រះពុទ្ធសាសនាជាសសរគ្រឹះចម្បងនៃសង្គមជាតិខ្មែរ ជាច្រើនរយឆ្នាំមកហើយ ។ ប៉ុន្តែតម្លៃរបស់ប្រជាជនខ្មែរ មិនមែនមានត្រឹមតែវិស័យសាសនា សីលធម៌ និងសង្គមកិច្ចទេ គឺមាននៅក្នុងវិស័យអក្សរសាស្ត្រ បច្ចេកទេស សេដ្ឋកិច្ច និងសិល្បៈផ្សេងៗ ទៀតដែរ ។

បើយើងសិក្សាតាមដំណើរប្រវត្តិសាស្ត្រ គឺចាប់ផ្តើមពីសតវត្សទី១ នៃគ្រិស្តសករាជ យើងមាន ឯកសារច្រើនបង្អួរ ស្តីពីស្ថានភាពស្រុកខ្មែរ និងជីវភាពនៃប្រជាជនខ្មែរ ។ ក្រោយមកទៀត ឯកសាររបស់ចិន និងឯកសារដែលគេរក្សាទុកនៅ "សាលាបារាំងនៃចុងបូព៌ាប្រទេស" (Ecole Francaise d'Extréme Orient) បានបញ្ជាក់ថា ប្រជាជនខ្មែរ មានការីរកចំរើនជាលំដាប់ ដោយសារមានការខិតខំប្រឹងប្រែងយ៉ាងស្វាហាប់ ដើម្បីឱ្យការចេះដឹងរបស់ខ្លួនកើតឡើងជាបន្តបន្ទាប់ ដែលជាលក្ខណៈពិសេស ថ្លៃថ្នូររបស់ជនជាតិខ្មែរតែម្តង ។

១- ការចេះដឹង ដែលបានមកពីឥណ្ឌា :

នៅឆ្នាំ ១៩៦0 អ្នកប្រាជ្ញបារាំងឈ្មោះ ហ្សង់ ហ្វីលីយ៉ូស្តាត៍ Jean Filliozat)[9] បានធ្វើសន្និសីទពី

[9] L´esprit da la civilisation khmére par M. Jean Fillizat, Professeur au Collége de France, Directeur de I´Ecole Francaise Orient, in *Cambodge d´Aujourd´hui*, janvier 1960, Phnom Penh, pp.1-23.

វប្បធម៌ខ្មែរ នៅវិទ្យាស្ថានគរុកោសល្យ នាទីក្រុងភ្នំពេញ ។ លោកបានពន្យល់ថា នៅក្នុងប្រវត្តិសាស្ត្រអារ្យធម៌ឥណ្ឌា បានជ្រាបចូលមកប្រទេសកម្ពុជា ជាលំដាប់ ។ តាមការពិត ខ្មែរមិនបាន "ធ្វើតាម" ឬ "ចម្លងតាម" វប្បធម៌ឥណ្ឌាគ្រប់វិស័យនោះទេ គឺខ្មែរបាន "ចាប់យក" គំនិតស្មារតីឥណ្ឌា ហើយបាន "បង្កើតជារូបរាងថ្មី" ដើម្បីទុកជាសមិទ្ធិកម្មរបស់ខ្លួនផ្ទាល់ ។ ដូច្នេះហើយ ទើបលោក ហ្សង់ ហ្វីលីយ៉ូស្តាត៍ បានតំណាត់សំគាល់ថា អក្សរខ្មែរដំបូងបង្អស់ គ្មានជាប់ទាក់ទងជាមួយនឹងអក្សរឥណ្ឌា ទោះក្នុងរចនាសម្ព័ន្ធក្តី ឬក្នុងការប្រើវាក្យសព្ទសំខាន់ៗក្តី ។ ជាបន្ទាប់មក គឺក្រោយពីវប្បធម៌ឥណ្ឌា បានចូលមកដល់ ទើបគេបានឃើញថា អក្សរខ្មែរ ដែលសរសេរលើសិលាចារឹកជាមុនដំបូងនោះ មានភ្ជាប់ជាមួយនឹងអក្សរនៃភាសាសំស្ក្រឹត (មកពីឥណ្ឌា) ព្រោះអក្សរខ្មែរ ត្រូវបានសរសេរភ្ជាប់នឹង (អក្សរសំស្ក្រឹតជាច្រើន ។

ឥណ្ឌា បានផ្សាយទ្រឹស្តីសាសនា និងអារ្យធម៌របស់គេទៅនៅគ្រប់តំបន់ រហូតដល់ប្រទេស ទីបេត៍ (Tibet) និងប្រទេសខ្មែរ ។ ប៉ុន្តែខ្មែរបានបង្កើតមូលដ្ឋាន

(តទៅលេខក្រោយ)



តក្កុ ជិន តេន ឥន្ទប្បញ្ញោ

សូមគោរពអង្គប្រជុំ

សូមចំរើនពរ លោកស្រី លោកស្រី និងពុទ្ធបរិស័ទទាំងឡាយ ។

ពេលនេះ យើងកំពុងនាំគ្នាធ្វើសិក្ខាសាលាមួយ ប្រធានបទ : **ខ្មែរមានពូជ** ។

ខ្មែរមានពូជ គឺខ្មែរយើងមានពូជល្អ។ មិនចាញ់ជាតិដទៃទេ ។ ខ្មែរយើងមានចំណេះវិជ្ជា មានចរិយាមារយាទ មានប្រពៃណី ទំនៀមទម្លាប់វប្បធម៌ល្អ។ មុនគេឯទៀតទាំងអស់ក្នុងអាស៊ីអាគ្នេយ៍នេះ ។ វាគ្មិន ពានាក់ សុទ្ធតែថ្នាក់បណ្ឌិត លោកបានលើកយកនូវពូជល្អ។ របស់ខ្មែរយើងជាច្រើន មកជម្រាបជាភស្តុតាងស្រាប់ហើយ ។ អាត្មា អនុមោទនាផង។ ឥឡូវដល់វេនអាត្មាហើយ នៅចុងក្រោយគេបំផុត អាត្មាអ្នកបួស អ្នកសាសនា អ្នកធម៌អាថិ ដូចនេះសូមជម្រាបផ្នែកសាសនាខ្លះ។ ដូចតទៅនេះ :

១-ពូជខ្មែរអ្នកប្រាជ្ញ : ខ្មែរយើងមានអ្នកប្រាជ្ញសូម្បីតែខាងសាសនា ក៏មានអ្នកប្រាជ្ញតាំងពីសម័យនគរភ្នំមក។ ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន មានព្រះសង្ឃអ្នកប្រាជ្ញខ្មែរពីអង្គ គឺព្រះសង្ឃបាលិ និងព្រះមន្ត្រសេន បានទិមន្តទៅជួយប្រែគម្ពីរពុទ្ធសាសនា មានគម្ពីរវិមុត្តិមគ្គជាដើម នៅប្រទេសចិន ។ (ពេលនោះប្រទេសជិតខាងយើង គេមិនទាន់ចូលមកនៅទឹកដីសព្វថ្ងៃនេះទេ លុះពេលគេចូលមក គេនៅអាស្រ័យទឹកដីយើង វប្បធម៌យើង ព្រោះគេមិនសូវមានវប្បធម៌ទេ) ។ សេចក្តីប្រែជាស្នាព្រះហស្ថរបស់ព្រះសង្ឃខ្មែរទាំងពីរព្រះអង្គនោះ កាលពីឆ្នាំ ១៩៥៦ សម្តេចសីហនុ យាងទៅប្រទេសចិន គេបានយកមកថ្វាយទត ទុកជានិមិត្តភាពខ្មែរ-ចិនផង ។ ខ្មែរត្រូវតែរក្សាទុកនូវពូជអ្នកប្រាជ្ញ គឺត្រូវខំសិក្សារៀនសូត្រឱ្យចេះដឹង ច្បាប់លាស់ពិតប្រាកដ មានកម្រិតខ្ពស់អាចទៅជាអ្នកប្រាជ្ញអន្តរជាតិបាន ។

២-ពូជខ្មែរនគរវត្ត : ព្រះបាទសូរិយាវរ្ម័នទី ២ បានសាងប្រាសាទនគរវត្ត បង្កប់ទុកនូវអត្ថន័យជ្រាលជ្រៅណាស់។ នគរមានន័យថា នគរ ឬជាតិ, វត្ត មានន័យថា វត្តឬសាសនា ។ ជាតិ និងសាសនាអាណាចក្រ និងសាសនចក្រ (ពុទ្ធចក្រ) ត្រូវជាមួយគ្នា រួមគ្នាគិតដោះស្រាយកសាង ការពារជាតិ សាសនា មិនមែនដាច់គ្នាស្រលះ គិតតែប្រយោជន៍ផ្នែកខ្លួន មិនគិតប្រយោជន៍ផ្នែកដទៃនោះទេ ប៉ុន្តែត្រូវគិតឱ្យជាតិរស់និងចំរើនរុងរឿងមុន ហើយសឹមជួយសាសនាឱ្យរស់ និងរុងរឿងបន្តបន្ទាប់ជាមួយគ្នាផងដែរ។ ពូជខ្មែរនគរវត្តនេះ ជ្រៅណាស់ សំខាន់ណាស់ កូនខ្មែរត្រូវតែយល់និងបដិបត្តិផងបាន។

៣- ពូជខ្មែរព្រហ្មបាយ័ន : ព្រះបាទជ័យវរ្ម័នទី ៧ បានសាងប្រាសាទព្រហ្មបាយ័ន ដែលមានសិរីសាព្រហ្មជាកំពូល។ បានសេចក្តីថា ខ្មែរត្រូវតែយកព្រហ្មវិហារធម៌៤ គឺមេត្តា ករុណា មុទិតា ឧបេក្ខា ជាកំពូល ជាមាគា សម្រាប់អនុវត្តន៍ ចាប់ផ្តើមពីអ្នកដឹកនាំគ្រប់ជាន់ថ្នាក់ ត្រូវតែមានព្រហ្មវិហារធម៌ សូម្បីតែប្រជាជន ក៏ត្រូវមានព្រហ្មវិហារធម៌រវាងគ្នានិងគ្នាដែរ ។ **(តទៅលេខក្រោយ)**

ឆានី ប្រវត្តិសាស្ត្រ ពីរជ្ជបាលកុលសម្ព័ន្ធមកដ្ឋាភិបាលសម័យ

ប្រែសម្រួលដោយ : ពិន សំខុន (តពីលេខមុន)

១៨ មិថុនា : ផ្លូវគមនាគមន៍ទាំង ៦ ភ្ជាប់ទៅភ្នំពេញ ត្រូវកាត់ផ្តាច់ ។

១៩-២១ កក្កដា : មហាសន្និបាតរណសិរ្ស និងបក្សកុម្មុយនីស្តខ្មែរ ប្រកាសជ័យជំនះទាំងស្រុងលើចក្រព័ទនិយមអាមេរិកាំង ។

៦ សីហា : ទម្លាក់គ្រាប់បែកលើ អ្នកល្បឿង ស្លាប់និងរបួសជាង ៤០០នាក់ ។

១២ សីហា : សីហនុ ផ្តល់បទសម្ភាសន៍មួយផ្សាយនៅកាសែត ញូយ៉កថែម និយាយថា " កាលណាពូកខ្មែរក្រហមលែងត្រូវការខ្ញុំ គេនឹងខ្ជាក់ចោលដូចគ្រាប់សីរីសអញ្ចឹងដែរ "... ។

១៥ សីហា : ទម្លាក់គ្រាប់បែករបស់ទ័ពអាមេរិកាំង ត្រូវបញ្ចប់ ។ គ្រាប់បែក ៥៣៩ ១២៩ តោន បានត្រូវទម្លាក់លើកម្ពុជា គឺជាឯកតទត្តកម្មពិភពលោកដ៏កំសត់ តាំងពីសង្គ្រាមលោកលើកទី២ មក (ជប៉ុនទទួលការទម្លាក់គ្រាប់បែក ១៦0.000តោន) ។

ចុងខែ សីហា : នៅតំបន់ ៣១ ខាងជើង កំពង់ចាម ក្បែរទន្លេមេគង្គ ដឹកនាំដោយ កែ ពក នៃបក្សកុម្មុយ-នីស្តខ្មែរ បានក្លាយទៅជាគំរូលួនៃការអនុវត្តន៍នយោបាយកុម្មុយនីស្តខ្មែរ នៅក្នុងប្រទេស (ប្រកាស ២0 ឧសភា) - អ្វីដែលបានកើតឡើងនៅតំបន់ ៣១ គឺដូចគ្នានឹងអ្វីដែលនឹងត្រូវកើតឡើងនៅកម្ពុជា ចាប់ពីឆ្នាំ ១៩៧៥ : វិន័យតឹងរឹងដូចដែកថែម - សម្លាប់មនុស្សទាំងក្រុម. បំផ្លាញរូបសំណាកព្រះពុទ្ធ. បំផ្លាញវត្តអារាម. បកស្បង់ចេញពីសង្ឃ. ការងារតឹងរឹងលំបាក. គ្មានផ្ទះសម្បែងផ្ទាល់ខ្លួន. កូនចៅ ប្តី ប្រពន្ធត្រូវបំបែកគ្នា ។

ខែ កញ្ញា : ស៊ីម វ៉ា បង្កើន "ចលនាមូលខ្មែរ" នៅប៉ារីស ។

៤ កញ្ញា : ឯកអគ្គរដ្ឋទូតអាមេរិកាំង លោក អេមូរី ស្វីង ចាកចេញពីភ្នំពេញ គ្មានអ្នកបន្តតំណែងទេ ។

៦-២៣ កញ្ញា : ចម្បាំងនៅកំពង់ចាម ចលនារណសិរ្ស មិនអាចយកឈ្នះបាន - ការប្រយុទ្ធមានកម្លាំងយ៉ាងសាហាវ ។

១-២ តុលា : ទ័ពរដ្ឋាភិបាលភ្នំពេញ ឥតមួយអាហារ ឥតប្រាក់ខែ នាំគ្នាបះបោរវាយគ្នាឯង ។

១0 តុលា : សហភាពសូវៀត ជាប្រទេសទី ៦២ ដែលទទួលស្គាល់រដ្ឋាភិបាលរណសិរ្ស - តែរក្សាភារ ធារី នៅភ្នំពេញ មិនដកចេញទេ ។

២២ តុលា : រដ្ឋាភិបាល អ៊ិន តាំ ទី២ (២២.១0.១៩៧៣ - ៧.១២.១៩៧៣)

. នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីមហាផ្ទៃ និងកំណែនទូទៅ : អ៊ិន តាំ

. ឧបនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកទំនាក់ទំនងជាមួយសភា និងសំរបសំរួលនៃនាយកដ្ឋានចរចា និងសន្តិភាព វប្បធម៌ និងសង្គមកិច្ច : ហង្ស ធន់ហាក់

តទៅលេខក្រោយ

ពុទ្ធប្បវត្តិអមដោយរូបភាព

A Pictorrial Biography of Saky amuni Buddha

❖ រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា

❖ បកប្រែជាភាសាអង់គ្លេស ដោយ ហ្សឺត .អេ.លឺ

❖ ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី

❖ បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ

៤៥- នៅពេលដែលកុមារីព្រហ្មចារិនីរូបនេះចូលមកដល់ទស្សនិកជនទាំងឡាយក៏ដូចជា ក្រុមមន្ត្រីដែលអង្គុយចាំពិនិត្យមើល សឹងបានសំគាល់ឃើញថា ព្រះរាជកុមារទ្រង់ភ្ញាក់ព្រះស្មារតីភ្លែតឡើងនៅពេលដែល បានឃើញនាង ។ ដូចជាកញ្ញា១ទាំងឡាយទៀតដែរ នាងដើរពីមុខព្រះរាជកុមារ ដាក់ភ្នែកក្រឡេកចុះក្រោម គោរពដោយអីមអៀន ។ ប៉ុន្តែក្រោយពីដើរផុតពីព្រះអង្គបន្តិចក៏ងាកមកសំលឹងមើលព្រះ-អង្គវិញ ប្រកបដោយទឹកមុនញញឹមប្រឹមប្រិយ ហើយក៏ទូលសួរព្រះអង្គថា "បពិត្រព្រះរាជកុមារ ! ព្រះអង្គមានរង្វាន់អ្វីសំរាប់ខ្ញុំម្ខាស់ឬទេ?" ព្រះអង្គទ្រង់ត្រាស់តបថា "ឱ្យបងសុំទោសរង្វាន់អស់ ហើយតែសូមប្អូនស្រីសំលាញ់ទទួលយកបរស់នេះជារង្វាន់ចុះ !" (លុះមានព្រះបន្ទូល ដូច្នេះហើយ) ទ្រង់ក៏ដោះខ្សែព្រះសុវានមាសដ៏ល្អឆើតបំពាក់ព្រះហស្តឱ្យនាង ។

៤៦-មន្ត្រីទាំងឡាយដែលព្រះរាជាទ្រង់ត្រាស់បញ្ជាឱ្យពិនិត្យមើល មានចិត្តសោមនស្សយ៉ាងខ្លាំង ដោយបានឃើញអាការៈយ៉ាងនេះ ។ គេបានដឹង និងស្គាល់យ៉ាងច្បាស់ថា បវរកញ្ញាដែលចូលមកដល់ក្រោយគេបង្អស់នេះ គឺព្រះនាង **យសោធរា** ជាព្រះរាជបុត្រីរបស់ព្រះមហាក្សត្រព្រះបាទ **សុប្បពុទ្ធ** ។ ពួកអាមាត្យ មន្ត្រីក៏បង្គំក្រាបទូលរឿងនេះដល់ព្រះបាទ សុទ្ធោទនៈ។ ក៏ទ្រង់បញ្ជូនមន្ត្រីឱ្យទៅថ្វាយបង្គំទូលព័ត៌មាននេះ ដល់ព្រះបាទ សុប្បពុទ្ធ ដើម្បីស្នើសុំចងស្ពានមានមេត្រីស្តីដណ្តឹងរាជកុមារីព្រហ្មចារិនីយសោធរា ទ្រង់រៀបរាជាភិសេកថ្វាយព្រះសុទ្ធត្ត រាជកុមារ ។

តទៅលេខក្រោយ

45- When this girl entered, the observers noticed that the prince was somewhat astonished. Like the other girls had done, she also walked before the prince, bashfully with bowed head. But after she had passed by, she looked backed smilingly and asked: "Any present for me?" The prince replied: "I am really sorry, but all the present are gone. Neck an exquisite golden chain and wound it about the girl's arm.

46- The officials who were ordered by the King to observe were very happy to see this. They discovered that the girl who had entered last was Yasodhara, the daughter of King Suppabuddha. They reported this of King Suddhodana, who sent his minister to visit King Suppabuddha, proposing that Province Yasodhara marry Prince Siddhartha.

(Continued Issue After)

(តមកពីទំព័រទី 01)

វិបត្តិនៅវិទ្យាល័យហ្វីឡា...

រឿនសូត្រនៅក្នុងសាលាមួយ ដែលយើងយល់ថា ពុំមានសុវត្ថិភាព ពុំមានសេចក្តីសុខ និងការគោរព - យើងសូមអំពាវនាវដល់មនុស្សចាស់នៅក្នុងសាលា ឬនៅក្នុងក្រសួងអប់រំទទួលខុសត្រូវលើបរិយាកាស គ្មានសុវត្ថិភាពនៅវិទ្យាល័យហ្វីឡាខាងត្បូង ដែលបានធ្វើឱ្យមានការលំបាកនឹងសិក្សានៅទីនោះ ។

ពេញមួយសប្តាហ៍បន្ទាប់មកដែលសិស្សរងគ្រោះធ្វើសកម្មភាពចេញពីវិហាគ្រិស្តសាលចិននៅ 55 N. Broad Street ឪពុកម្តាយសិស្ស និងអង្គការសង្គមស៊ីវិលជាច្រើនបានចូលរួមមានសមាគមន៍ខ្មែរ-សម្ព័ន្ធអាស៊ានអាមេរិកាំង -សេវាអ្នករងគ្រោះនិងសាក្សីអ្នកការពារក្តីអាស៊ានអាមេរិកាំង ដោយមានការថ្កោលទោសថា ក្រសួងអប់រំ ពុំមានប្រតិកម្មអ្វីច្បាស់លាស់ នឹងរហ័សរហួនទេ ។ បាតុកម្មគាំទ្រសកម្មភាពតស៊ូទាមទារឱ្យមានសុវត្ថិភាពនៅតាមសាលារៀនរបស់សិស្សបានចូលលុកដោយសន្តិវិធីក្នុងអង្គប្រជុំរបស់ក្រសួងអប់រំនាថ្ងៃពុធ ខែធ្នូ បន្ទាប់ មកទាមទារឱ្យមានចម្លើយជាបន្ទាន់ដល់ការទាមទាររបស់ក្រុមសិស្សពីសំណាក់នាយកក្រសួងអប់រំ អាក់លីន អាគីម៉ាន់ តែនៅតែពុំ មានសកម្មភាពច្បាស់លាស់ដដែល ពីក្រសួង នាថ្ងៃនោះដដែលៗ បាតុកម្មនៅវិហារគ្រិស្តសាសនាចិន នៅមានដដែល រហូតដល់ថ្ងៃអាទិត្យទី ១៣ របស់អ្នកគាំទ្រសកម្មភាពសិស្សគ្មានការទាក់ទងពីក្រសួងឬសាលាទៅឪពុក ម្តាយឬសិស្សរងគ្រោះម្តងណានៅឡើយទេ គេដឹងថា នៅពេលនោះថាក្រុមការពារក្តីអាស៊ានអាមេរិកាំង នឹងមូលនិធិសិក្សាបានត្រៀមដាក់ពាក្យប្តឹងទៅតុលាការកាលពីថ្ងៃសុក្រ ចំពោះការរំលោភសិទ្ធិពលរដ្ឋរបស់ក្រសួងអប់រំ នៅហ្វីឡាដែលហ្សៃ ដែលបណ្តាលឱ្យអំពើហិង្សាចេះតែកើតឡើងរាល់ថ្ងៃ។ នៅថ្ងៃសុក្រនោះ ក្រសួងអប់រំ (School District) និង នាយកវិទ្យាល័យ ឡាត្រែតា ប្រោន បានប្រកាសគោលការណ៍ចំ១នៃសន្តិសុខថ្មីរបស់សាលារៀន តែក្រុមសិស្សក្លូកម្មពុំបានឆ្លើយតបនឹងសេចក្តីប្រកាសថ្មីនោះឡើយដែរ ដោយរង់ចាំការស៊ើបអង្កេតអំពីឧប្បត្តិហេតុដែលធ្វើឱ្យមានការរងគ្រោះដល់សិស្សរបស់ក្រសួងអប់រំ- ក្រសួងអប់រំក៏បានបង្ហាញបំណងមួយទៀត ថានឹងធ្វើការស៊ើបអង្កេតដោយអង្គការឯករាជ្យមួយ ។

ថ្ងៃច័ន្ទទី ១៤ ធ្នូ មានកិច្ចប្រជុំសំខាន់មួយ រវាងអ្នកគាំទ្រសិស្សក្នុងសហគមន៍ និងអាជ្ញាធរ សាលាដោយមាន អ្នកសង្កេតការណ៍ឯករាជ្យ ចូលរួមផងនៅវិហារជ្រុងផ្លូវ "អាក"និង"ប្រ៊ក" ខាងជើងសាលាក្រុង ដែលជាដំណាក់កាលដំបូងនៃការចរចាគ្នារកដំណោះស្រាយ ។

អ្នកស្រី អាគីម៉ាន បានយល់ស្របនឹងក្រុមនិស្សិតថា "បញ្ហារប្បៀបនេះមានមកពីយូយា ណាស់មកហើយ លើសពីសមត្ថកិច្ចរបស់សាលារៀនចូលទៅដល់សហគមន៍ទៅហើយ" ។

ខេឃីយុងសុន យូ ប្រធានគណៈកម្មាធិការទំនាក់ទំនងមនុស្សនៅសាលាក្រុងនិយាយថា "ស្ថានភាពនេះពុំមែនត្រឹមតែជាទំនាស់ពណ៌ សម្បុរស្បែកទេ តែវាក្លាយទៅជាធ្ងន់ធ្ងរនៅពេលមានចំណេះខាងភាសាតិចតួចរបស់សិស្សអាស៊ានខ្លាំ...ដែលបានធ្វើឱ្យការប្រស្រ័យទាក់ទងគ្នាក្លាយទៅជាការលំបាក..." **តទៅទំព័រទី ១៨**

តោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.

បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 យ៉ាច

១_មុខជំនាញខាងម្ហូបខ្មែរយ៉ាង ចំណាន រួចជា:

- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្តាំង ឆារសាច់គោ
- មីកន្តាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ងង

២_មុខជំនាញម្ហូបវៀតណាម ឈ្ងុយឆ្ងាញ់ រួចជា:

- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកត្រឡុកត្រូបរស់ជាតិផ្លែឈើ ដូចជា : ឪរ៉ែន ឬ អាតុកាដូ ហើយជាពិសេស មានទឹកអំពៅក៏ឥតស្តួសៗ

ជីវិតជាតិខ្មែរក្រោយថ្ងៃ ៧ មករា ៧៩



ដោយ : លោក ម៉ម យីន

ប្រាំពីរមករា ចិតប្រាំបួន
សង្គ្រោះជាតិខ្មែរទាំងប្រុសស្រី
ប៉ុន្តែក្រោយមកជាច្រើនខែ
ទ័ពយួនមកនេះប្រកាដជា
ពិសេសពេលនោះខ្មែរដឹងច្បាស់
បន្តឱ្យស្ពាប់ថែមទៅទៀត
ទ័ពយួនពីរសែនណែនពេញស្រុក
នាំទៅស្រុកយួនយ៉ាងសប្បាយ
ធ្វើឱ្យទ័ពយួនមានកំហឹង
ដេញខ្មែរក្រហមដែលជាខ្មាំង
ពេលនោះជាតិកើតភ័យខ្លាច
ខ្មែរត្រូវនៅស្ងៀមបើចង់បាន
ខ្មែរឃើញផ្លូវច្មោះបានសម្រេច
ជួយខ្លួនបានរួចពីភ័យភិត
ដើរទៅខាងលិចជាជាយដែន
ពេលនោះជាពេលសំណាងណាស់
អង្គការសហប្រជាជាតិ
ជាស្បៀងអាហារខោអាវភួយ
រួចហើយនាំគ្រាច់ចេញទៅ
រស់នៅស្រុកក្រៅជាជាប់លាប់
ខ្មែរសែនត្រេកអរមានវាសនា
បានសុខចិត្តកាយលែងចង្អៀត
សង្គមជាតិខ្មែរត្រូវបែកបាក់
ទោះបីមករស់សុខក៏ដោយ
នឹកឡើងសែនខឹងនឹងពួកព្រៃ
សម្លាប់ជាតិខ្មែរគ្មានប្រណី
ក្រហមដូចគ្នា ចាស់ និងថ្មី
តាមពិតកលល្បិចយួនទាំងអស់
ធ្វើឱ្យមេខ្មែរមានអំណាច
បានដឹកនាំខ្មែរដោយគ្មានព្រួយ
ខ្មែរនៅក្រៅស្រុកក្អកក្តួលណាស់
ប្រទេសជាតិខ្មែរត្រូវជាប់ស្អិត
នាំជាតិឱ្យធ្លាក់ក្នុងគ្រោះថ្នាក់
ជាតិខ្មែរខ្ចាត់ខ្ចាយព្រាចបាចសាច

ថ្ងៃនេះទ័ពយួនបានជោគជ័យ
បានរស់ផុតភ័យក្តីវេទនា ។
មានជនជាតិខ្មែរគិតឃើញថា
កំចាត់ខ្មែរណាស្នេហាជាតិ ។
ពេលនេះយួនឈ្លេនពិតពិឃាដ
ដោយប្រើល្បិចស្នើតបង្អត់បាយ ។
រឹបទ្រព្យគ្រប់មុខសែនរីករាយ
ជាតិខ្មែរកើតស្តាយក្រោកប្រឆាំង ។
ព្រោះខ្មែរទៅពឹងឱ្យមកច្បាំង
ម្តេចខ្មែរអារាំងចោទបំពាន ។
ទ័ពយួនសែនកាចបានព្រមាន
ចង់សុខរស់វានមានជីវិត ។
នាំគ្នាដើរគ្រាច់រកផ្លូវពិត
នាំគ្នាតាំងចិត្តចេញចោលផ្ទះ ។
ខ្មែរច្រើនរាប់សែនទាំងក្មេងចាស់
អង្គការយល់ច្បាស់ចេញមកជួយ ។
អង្គការលួសា្តតនាំជំនួយ
ថ្នាំពេទ្យលើកសួយជនឈឺចាប់ ។
រកញាតិពង្សផៅពីមុនស្រាប់
នាំចេញប្រញាប់ជួបជុំញាតិ ។
ចាកចេញតគ្នាយ៉ាងព្រោងព្រាត
ជាមួយក្រុមញាតិឃ្លាតយូរហើយ ។
ព្រាត់ប្រាសគ្នាជាក់ទុក្ខគ្មានស្បើយ
ចិត្តមិនល្អែល្អើយពីទុក្ខភ័យ ។
ក្រហមពេកក្រៃចិត្តព្រៃផ្សៃ
រួចហើយដោះដៃថាសង្គ្រោះ ។
គ្រាន់តែក្រឡៃថារំដោះ
មួយសម្លាប់ស្មោះ មួយទៀតជួយ ។
ដោយចិត្តអង់អាចយួនលើកសួយ
មានតែខ្លួនមួយជួយជាតិពិត ។
ព្រោះមើលឃើញច្បាស់នៅក្នុងចិត្ត
ក្នុងដៃមេស្និទតែអំណាច ។
មហន្តរាយជាក់ត្រូវភ័យខ្លាច
អស់ក្តីអង់អាចត្រឹមនេះហោង ॥

(តមកពីទំព័រទី ០៥)

រឿនសន្សំតែក់ៗ...

- អ្នកបច្ចេកទេសខាងអគ្គីសនី បានសន្យាថា អំពូលភ្លើងឈ្មោះ "Nivision" មិនសូវចំណាយកម្លាំងអគ្គីសនីខ្លាំងប៉ុន្មានទេ តែមានតម្លៃខ្ពស់ជាងអំពូលភ្លើងធនធម្មតា ក៏ប៉ុន្តែរបស់នេះ មានគុណភាពល្អ ហើយអាចប្រើបានយូរទៀត ដូចជាអ្នកចាំផ្តើមមូលក្បុងតាក់បើក អំពូលភ្លើងនេះចាប់ចេញពន្លឺស្រទន់ ពីតូចព្រឹម។ ឡើងទៅភ្លឺច្បាស់បន្តិច។ម្តងនេះបង្ហាញឱ្យឃើញថា ចរន្តអគ្គីសនីរត់ទាញតិច។ ។

- អ្នកគួរបន្ថាយចំនួនអំពូលភ្លើងខ្លះ នៅតាមបន្ទប់ ដូចជាបន្ទប់ទទួលទានដំណេក ឱ្យពន្លឺត្រឹមតែភ្លឺច្បាស់ល្មមមើលឃើញបាន ។

- អ្នកគួរជៀសវាងបើកទ្វារទូទឹកកកចំហរចោលយូរ ដូចជា អ្នកត្រូវការបើកយកទឹកពិសារ ចាក់ទឹកដាក់កែវរួចបានដើរចេញ ហើយទើបបិទទ្វារទូទៅវិញ ចំណាប់នេះគួរអ្នកជំរុះចោល ពីព្រោះអ្នកបច្ចេកទេសបានរកឃើញថា នៅពេលទ្វារទូទឹកកកចំហរខ្យល់ត្រជាក់ហើរចេញទៅក្រៅ ចំរាំអ្នកបិទទ្វារមកវិញ ខ្យល់ក្តៅពីខាងក្រៅចូលមកជំនួស ដូច្នេះចរន្តអគ្គីសនីត្រូវរត់ទាញជាខ្លាំង ដើម្បីធ្វើខ្យល់ក្តៅនោះឱ្យត្រជាក់ទៅដល់កំរិត ដែលអ្នកបានកំណត់ក្នុងទូទឹកកកនេះវិញ ។

5. សន្សំប្រាក់ចំណាយលើទឹក :

នៅទីក្រុងខ្លះ ដែលមានភ្ជុំច្រើន មិនសូវសម្បូរភ្លៀងធ្លាក់ ដូចជា California អាជ្ញាធរបានចេញប្រកាសឱ្យប្រជាពលរដ្ឋរៀនសន្សំសំចៃទឹក ដោយមានកំណត់ក្នុងការប្រើប្រាស់ ដូចជា មានពេលម៉ោងកំណត់ស្រោចស្មៅ និងដំណាក់ក្នុងភូមិ ។

នៅទីកន្លែងដទៃទៀត គេកំណត់ឱ្យប្រើទឹកក្នុងបន្ទប់ទឹក ដូចជាមុជ និងប្រើបង្គន់ គឺគេកំណត់ឱ្យមុជស្រោចខ្លួន ហាមមិនឱ្យមុជត្រាំ រីឯបង្គន់អ្នកបង្ហូរទឹកចេញនៅពេលដែលចាំបាច់ប៉ុណ្ណោះ ។ ការសន្សំសំចៃរបៀបនេះ វាពិតជាមានភាពចង្អៀតចង្អល់មែន តែក៏ជាការចំលាប់ដ៏ប្រសើរមួយដែរ ។

ការសន្សំទឹកមិនមានត្រឹមតែស្រោចដំណាំ ឬក៏បន្ទប់ទឹកទេ អ្នកក៏ត្រូវមានស្មារតីប្រុងប្រយ័ត្នទៅលើរបស់ផ្សេងៗទៀត ដូចជា Sink លាងចាន មូលក្បាលទឹកបិទហើយ តែទឹកនៅតែស្រក់តក់ៗ ទៀតគួរអ្នកយកថ្តិល ឬក៏ធុងណាមួយតូចល្មមមកត្រង់ទឹកទុក អាចប្រើទឹកនោះលាងចាន ឬទុកស្រោចដំណាំក៏បាន ចំរាំដល់ឱកាសអ្នកអាចជួសជុលបាន ។ ម្យ៉ាងទៀត បើអ្នកឮទឹកហូរមិនឈប់នៅបន្ទាប់ពេលអ្នកប្រើបង្គន់ហើយ ពេលនោះអ្នកត្រូវឆាប់ពិនិត្យរកមូលហេតុ ជួនកាលកៅស៊ូនៅខាងក្នុង Toilet Tank បិទមិនជាប់ ឬក៏ត្រូវផ្លាស់ថ្មី ។ នៅពេលអ្នកលាងបន្លែ ឬផ្លែឈើ អ្នកអាចទុកទឹកនោះស្រោចស្មៅ ឬដំណាំបន្តិចបន្តួចក៏បាន អ្នកគួរជៀសវាងបើកទឹកបង្ហូរចោលនៅពេលអ្នកលាងចាន ឬលុបលាងមុខមាត់ ។

មានមតិខ្លះគេយល់ថា មានតែអស់លោកស្ត្រីៗទេ ដែលអាចចេះសន្សំសំចៃដូច្នេះបាន គួរឱ្យខ្មាស់ដែរចំពោះអស់លោកប្រុសៗ តែមិនទាន់ជាយឺតយ៉ាវទេ ॥

New World Travel II
ភ្នាក់ងារធ្វើដំណើរ
Specialized in Selling Flight Tickets
For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉ែ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

(តមកពីទំព័រទី ០៣)

សមាគមខ្មែរមានអាយុ...

"We are here today in this wonderful space to celebrate those who have served or is continuing to serve, and to also celebrate those younger generations, as you see will be our bridge to the future. Again we are here to celebrate…to honor the past, and to shape our future together."

CAGP's current President Somrith Pon Som also stated that the reason for the event's existence was "to make sure that we recognize, make sure that we enjoy these thirty years of achievement, and in a way of also bringing people together and resource and educate the general public that after thirty years we're not going away. The situation is still here. I mean the suffering is still here. The lingering of the past is still here. People still suffer mentally and physically. Sometimes, if we don't do this, I think that a lot of people will not hear the information."

The event not only celebrated CAGP's service to the Cambodian-American community since 1979 but to also recognize the Cambodian heritage, voices of community members, and to also celebrate CAGP and their achievements.

ហោរាសាស្ត្រប្រចំថ្ងៃទី ២៤ ធ្នូ - ០៩ មករា

ឆ្នាំជូត : (ពស្យធេណ្ឌាឃ្លួស ចាតុធីក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ដោយចំនាយទាយថា អាចបង់ខាតទ្រព្យខ្លះៗនោះ ដូច្នេះចូរកុំឱ្យគេខ្ចីរបស់របរមានតម្លៃឡើយ ព្រោះកាល បើបានធ្លាក់ដល់ដៃគេហើយ គឺគ្មានថ្ងៃបានវិលត្រលប់វិញឡើយ ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេលនេះ មានផលប៉ះទង្គិចគ្នាខ្លះ ។

ឆ្នាំឆ្លូវ : (ពស្យមនុស្សឃ្លួស ចាតុជី)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះលោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិតប្រាជ្ញាឈ្លាសវៃ ទោះបានប្រកបការងារអ្វីក៏អាចទទួលបានផលសម្រេចតាមការប៉ងប្រាថ្នាទាំងអស់ ។ តែចូរកុំមានចិត្តលោភលន់ឱ្យហួសប្រមាណពេកប្រយ័ត្នបង់ខាតលាភសក្ការៈទៅវិញ ។ ចំពោះគូស្នេហ៍មានភាពលូកលុំនលុណាស់ ។

ឆ្នាំខាល : (ពស្យយក្សស្ត្រី ចាតុឈើ)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូររៀបចំគម្រោងផែនការជាមុន ទើបពុំមានការថ្នោះធ្នោយ ។ ក្រៅពីនោះបើមានរឿងឈ្លោះវិវាទកើតឡើង ចូរចេះអត់ធ្មត់ និងរង់ចាំចិត្តឱ្យបានត្រជាក់ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះច្រើនពាក់មុខយក្សដាក់គ្នា ॥

ឆ្នាំថោះ : (ពស្យមនុស្សស្ត្រី ចាតុឈើ)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាក។ច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូរកុំធ្វេសប្រហែសឱ្យសោះ ជាពិសេសក្នុងការទូទាត់បញ្ជីប្រាក់កាសផ្សេង។ព្រោះកាលបើមានការភ្ញាំងភ្ញាត់តែបន្តិចអាចខាតបង់ទ្រព្យច្រើន ដែលមិនអាចគណនាបានឡើយ ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេលនេះ ប្រយ័ត្នមានគេអុជអាលឱ្យបែកបាក់គ្នា ॥

ឆ្នាំរោង : (ពស្យធេណ្ឌាឃ្លួស ចាតុមាស)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែការងាររកស៊ីនៅជួបនឹងឧបសគ្គខ្លះ។ក្តី ក៏មិនភ័យព្រួយអ្វីដែរ លោកអ្នកអាចទម្លុះទម្លាយបានដោយជោគជ័យ និងអាចបោះជំហានទៅមុខដោយសន្សឹមៗ ទៀតផង ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ គឺអាចគិតគូរឿងអាពាហ៍ពិពាហ៍បាន ॥

ឆ្នាំឃ្លាញ់ : (ពស្យមនុស្សឃ្លួស ចាតុឆ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ អ្វីដែលលោក-អ្នកគ្រូវិយកចិត្តទុកដាក់នោះ ចូរប្រយ័ត្នប្រយែងក្រែងមានបងប្អូនញាតិមិត្តនាំរឿងក្តៅក្រហាយមកឱ្យអាចនាំឱ្យមាន អំពល់ទុក ដាក់ខ្លួន ព្រមទាំងអាចបង់ខាតទ្រព្យច្រើនទៀតផង ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ មានភាពស្និទ្ធស្នាលដូចធម្មតា ॥

ឆ្នាំមមី : (ពស្យធេណ្ឌាស្ត្រី ចាតុឆ្លើង)

រាសីលោកអ្នកចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរ ជួបនឹងឧបសគ្គច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសចំពោះអាជីវកររកស៊ីជួញដូរគឺមុននិងប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យមើលគុណភាព និងរាប់ចំនួនឱ្យបានត្រឹមត្រូវទើបមិនចាញ់បោកគេ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមិនសូវចុះសម្រុងគ្នាទេ ॥

ឆ្នាំមមែ : (ពស្យធេណ្ឌាស្ត្រី ចាតុមាស)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ លោកអ្នកជាមនុស្សពូកែខាងសម្តីវោហារ ហើយបើបានធ្វើជាមេគេ និងទោះជាបាននិយាយស្តីច្រើនបន្តិចក្តី ក៏មិនឥតប្រយោជន៍ដែរ ព្រោះត្រូវបានកូនចៅនៅក្រោមស្តាប់បង្គាប់បញ្ជាឥតហ៊ានងាករេឡើតផង ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះប្រកបដោយភាពផ្អែមល្ហែមដូចទឹកឃ្មុំ ॥

ឆ្នាំឆក : (ពស្យយក្សឃ្លួស ចាតុជើក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ពិតមែនតែលោកអ្នកបានជួបនឹងឱកាសល្អខ្លះៗក្តី តែទោះជាបានប្រកបការងារអ្វីក៏ដោយ ចូរកុំធ្វេសប្រហែសឱ្យសោះ ជាពិសេសមុននិងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើលិខិតស្នាមផ្សេងៗ ចូរចេះពិនិត្យពិច្ឆ័យឱ្យបានល្អិតល្អន់ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះចេះយល់អធ្យាស្រ័យគ្នាធម្មតា ॥

ឆ្នាំរកា : (ពស្យយក្សឃ្លួស ចាតុជើក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមការប៉ងប្រាថ្នាទាំងអស់ ។ លោកអ្នកអាចបណ្តាក់ទុនរកស៊ី ឬចេញទៅជួញដូរផ្លូវឆ្ងាយគឺសមប្រកបទាំងអស់ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ॥

ឆ្នាំច : (ពស្យយក្សស្ត្រី ចាតុជី)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាស្មុគស្មាញច្រើន ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែលោកអ្នករត់ចុះរត់ឡើងមានការមមាញឹក និងហត់នឿយច្រើនក្តី តែភោគផលកម្រៃហូរចូលបានគិចតួចស្តួចស្តើងប៉ុណ្ណោះ ។ ដូច្នេះចូរកុំរកបានមកដោយគឹងតែចាយចូរឱ្យសោះ ។ ចំពោះស្នេហាក្នុងរយៈពេលនេះ ប្រយ័ត្នមានអ្នកទី៣ ចូលជ្រៀតជ្រែក ॥

ឆ្នាំកុរ : (ពស្យមនុស្សស្ត្រី ចាតុធីក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលថ្វីត្បិតតែការងាររកស៊ីរបស់លោកអ្នកបានជួបនឹងគូប្រជែងដើងខ្លាំងយ៉ាងណាក្តី ក៏មិនភ័យព្រួយអ្វីដែរ ព្រោះលោកអ្នកយកប្រៀបឈ្នះជាប់ជានិច្ច ។ ចំពោះកម្លោះក្រមុំ ក្នុងរយៈពេលនេះអាចទាក់ទងគ្នា និងបានក្លាយជាគូស្នេហ៍ដ៏ប្រពៃមួយគូ ។

មានអ្វីប្លែកនៅហ្វីឡាដែលហ្សៀ

១- ឱ្យរង្គាន្យាពេលឱ្យចំណេញពន្ធអ្នកទិញផ្ទះលើកដំបូង :

•••ចាប់ពីខែតុលា មុននោះមក ចំនួនផ្ទះដែលលក់ចេញបាននោះ ឡើងចំនួន ១០.១% ។ គឺជាចំនួនដ៏ច្រើនលើសលប់ប្រៀបធៀបទៅនឹងឆ្នាំមុន។ ដែលផ្ទះបានចុះថ្លៃលក់ ហើយលក់មិនដាច់ទៅទៀត ។ ការឡើងចំនួន នេះបណ្តាលមកពីរដ្ឋជួយឱ្យរួចពន្ធ ៨០០០ដុល្លារ ដល់អ្នកទិញផ្ទះជាលើកទី១ ហើយឱកាសដែលល្អដែលទើបនឹងបញ្ចប់នាថ្ងៃទី៣០ វិច្ឆិកា ២០០៩ បានត្រូវពន្យាពេលរហូតដល់ខែមេសា ឆ្នាំ២០១០ វិញ ដោយសភាអាមេរិកាំង ។ ដោយសារច្បាប់ដ៏មានអំណោយផលនេះ អ្នកជួលផ្ទះជាច្រើនឱកខំស្វែងទៅទិញ ឱ្យក្លាយទៅជាម្ចាស់ផ្ទះវិញ ។

ការទិញផ្ទះ គឺជាការគិតទៅឆ្ងាយ ដោយជាទូទៅគេគិតថាយ៉ាងហោចណាស់ក៏នៅក្នុងផ្ទះរបស់ខ្លួនបាន១០ឆ្នាំដែរ ។ បើមានការងារធ្វើហ្នឹងនំ គិតថា ទិញផ្ទះពេលនេះ ពិតជាសមរម្យហើយ ។ តំបន់ដែលគ្មានឧក្រិដ្ឋកម្ម-មានសោភ័ណ្ឌភាពប្រសើរ-មានអ្នកជិតខាងចេះថែរក្សាស្រុកភូមិ គឺជាកត្តាសំខាន់សំរាប់ទិញផ្ទះ កុំប្រញាប់ប្រញាល់ ដោយសារនេះជាវិនិយោគពេលយូរ ។

បើទិញផ្ទះសំរាប់ជួលត្រូវដឹងថា ជាទូទៅផ្ទះនៅទំនេរគ្មានគេជួល មាន ៥% នៃទីផ្សារជួលផ្ទះ - នៅទូទាំងប្រទេសមានផ្ទះទំនេរ ៧.៤% - សម្រាប់ហ្វីឡា គឺ ៧.១% ឥឡូវនេះធ្លាក់ចុះ ៤.១% ថែមទៀត ។ តួលេខនេះតម្រូវឱ្យអ្នកទិញផ្ទះសម្រាប់ជួលពិចារណាថែមទៀតដែរ ។ **សមាគមជាតិខាងទិញ-លក់ផ្ទះ !**

២_ ខ្មែរហ្វីឡា ទៅ អ.ស.ប

•••សហគមន៍ខ្មែរ និងគណបក្ស សម រង្ស៊ី មួយក្រុម បានចេញដំណើរពីហ្វីឡាដែលហ្សៀ ទៅកាន់វិមាន អ.ស.ប ដើម្បីយកសេចក្តីរាយការណ៍ ស្តីពីការរំលោភសិទ្ធិមនុស្សនៅកម្ពុជា ទៅជូនសន្និសីទសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ នៅទីក្រុងញូយ៉ក នាឱកាសប្រារព្ធទិវាសិទ្ធិមនុស្សពិភពលោក ថ្ងៃទី ១០ ធ្នូ ឆ្នាំ ២០០៩ ॥

ការពារកែងជើងដែលប្រេះ

...ចំណុចនេះអ្នកដែលព្រួយបារម្ភជាង់គេបង្អស់ នោះពិតជាគេចមិនផុតពីសុភាពស្ត្រីនោះឡើយ ព្រោះនាង់ជាភេទអភិរក្សសម្ផស្សជាង់បុរសភេទ ។

បញ្ហាកែងជើងប្រេះគឺជាបញ្ហាមួយដែលយើងប្រទះឃើញកើតមានជាញឹកញាប់ទៅលើមនុស្សវ័យកណ្តាល ជាពិសេសអ្នកដែលមិនចូលចិត្តពាក់ស្បែកជើង ហើយមានការធ្វើដំណើរជាប់ជាប្រចាំនោះ ។ ការព្រងើយកន្តើយក្នុងការថែបំប៉នយកចិត្តទុកដាក់អាចធ្វើឱ្យស្បែកកែងជើងប្រេះក្លាយទៅជាចង្អូរដែលមិនល្អសំរាប់អ្នកដែលបានប្រទះឃើញ ។

វិធីការពារអាការប្រេះកែងជើងអាចធ្វើបាន ដោយង៉ាយៗដែលក្នុងខណៈពេលងូតទឹក ស្បែករមែងផ្ទើងធុនពេលនោះណែនាំអ្នកឱ្យប្រើឬដែលប្រើសំរាប់ដុសក្អែលមកដុសនៅត្រង់កែងជើង ដែលមានស្បែកក្រាស់ជាង់ធម្មតានោះ ដោយថ្នម ។ បន្ទាប់មកយើង់អាចកាត់ស្បែក ចំណែកខ្លះដែលប្រេះចេញបន្តិចបន្តួចដោយធ្វើយ៉ាង់នេះយ៉ាង់ហោចណាស់១សប្តាហ៍ម្តង់ ឬក៏អាចប្រើទឹកក្តៅដាក់ត្រាំជើង់ទុកប្រមាណពី១៥-២០ នាទី ។ រួចហើយប្រើសំបកក្រូចថ្មាដុសត្រង់បរិវេណកែងជើងប្រេះបែក ដើម្បីជួយបំលាស់ កោសិកាស្បែកដែលង៉ាប់ឱ្យជ្រុះចេញ ។

មូលហេតុដែលធ្វើឱ្យស្បែកត្រង់បរិវេណកែងជើងង៉ាយប្រេះជាង់បរិវេណកែងជើងង៉ាយប្រេះ ជាង់បរិវេណដទៃនោះ ដោយសារស្បែកបរិវេណ នេះមានក្រពេញខ្លាញ់តិច ទើបមិនសូវមានក្លិនហូរចេញមកជួយស្រោបស្បែក ទើបធ្វើឱ្យបរិវេណស្បែកបាតជើងឡើងក្រៀមស្ងួតង៉ាយនឹង៉ាយប្រេះបែកបំផុត ។ បន្ទាប់ពីងូតទឹករួចរាល់ហើយ គួរលាបក្រែមឱ្យបានជោកជាំ រួចហើយឈ្លីកែងជើង និង់បាតជើងរហូតដល់សាច់ក្រែមជ្រៀតចូលទៅក្នុងសាច់ ប្រសិនបើធ្វើបានលើកនេះជានាថា ស្បែកបរិវេណកែងជើងរបស់អ្នកនឹង៉ាមិនប្រេះបែក ហើយមានសភាពទន់ជានិច្ច ॥

ទប់ស្កាត់រោគមហារីកក្រពះនោម ដោយបន្ថែស្ពៃក្តោបពណ៌ស្វាយ

•••សំរាប់អ្នកដែលនិយមទទួលទានបន្ថែស្ពៃក្តោបពណ៌ស្វាយ ឬដែលជាទូទៅគេ និយមហៅថាប្រ៉ុកគូលី នោះ ប្រហែលជាពុំបានជ្រាបទេ ថាបន្ថែស្ពៃប្រភេទនេះ វាហុចផលល្អដោយចំៗ ក្នុងការការពារឬកាត់បន្ថយបានទូវអាការរាលដាលរោគក្រពះអាហារបាន ។

ការស្រាវជ្រាវមួយនាពេលថ្មីៗកន្លងទៅនេះ គេបានរកឃើញថា សារជាតិប្រភេទខ្លះដែលមាននៅក្នុងបន្ថែស្ពៃក្តោបពណ៌ស្វាយនេះវាជួយពន្យារការលូតលាស់នៃកោសិការោគមហារីកក្នុងក្រពះនោមបាន ។ ទាំងអស់នេះក៏ព្រោះថា ស្ពៃប្រ៉ុកគូលីនិងបន្ថែអំបូរស្ពៃក្តោបមានសារជាតិប្រភេទខ្លះអាចជួយពន្យារការលូតលាស់របស់កោសិការោគមហារីកបាន ។

ទិន្នន័យនេះគេទទួលបាន បន្ទាប់ពីបានធ្វើពិសោធន៍ពីការប្រើសារជាតិចំរាញ់ចេញពីស្ពៃប្រ៉ុកគូលី ចូលទៅក្នុងបំពង់ពិសោធន៍ ដែលប្រើចិញ្ចឹមកោសិកាមហារីកក្រពះនោម ដែលកំពុងមានការវិវត្តន៍យ៉ាងឆាប់រហ័សនោះ ក៏រកឃើញថាមានការកាត់បន្ថយបានយ៉ាងឆាប់រហ័ស ។ សារជាតិទុកស្កាត់ជាមួយរោគមហារីក ដែលមាននៅក្នុងបន្ថែស្ពៃប្រ៉ុកគូលីនោះ គួរជាសារជាតិម្យ៉ាងនៅក្នុងក្រុម Isothiocyanat នោះឯង ។

បន្ទាប់ពីបានជ្រាបនូវអាថិកំបាំងបែបនេះហើយសូមកុំភ្លេចព្យាយាមទទួលទានបន្ថែស្ពៃក្តោបពណ៌ស្វាយឱ្យបានច្រើន ដើម្បីសុខភាពទាំងអស់គ្នា ॥

(តមកពីទំព័រទី ១៥)

វិបត្តិនៅវិទ្យាល័យហ្វីឡា...

តែអ្នកស្រី អគីម៉ាន បានបញ្ជាក់ថា "នឹងពុំមានក្រុមណាមួយដែលជឿថា ពួកខ្លួនពុំបានត្រូវគេយកចិត្តទុកដាក់ស្តាប់ខ្លួននោះទេ" អ្នកការសែត "អឹកក្វាយរ៉" បានអានវេបសាយរបស់ក្រសួងអប់រំ (School District) ដែលបានបញ្ជាក់ថា ក្នុងចំណោមសិស្ស ១.១៧៥ នាក់ នៃវិទ្យាល័យហ្វីលីខាងត្បូងមាន ៧0% ជាអាហ្រ្វិកាំង អាមេរិកាំង ៥.៦% ជា ស្បែកស-១៨.៣% ជាអាស៊ាន និង ៥.២% ជាឡាទីណូ។ នាចន្លោះឆ្នាំ ១៩៥0 មក ២000 សិស្សអាស៊ានបានកើនឡើងពីរដងនៅតំបន់ហ្វីឡាដែលហ្វីយ៉ានេះ មាន ចិន-ខ្មែរ-វៀតណាម ដែលគ្រប់គ្រងអភិវឌ្ឍន៍នៅក្នុងតំបន់តែប្រទេសទូវទំនាស់រវាងសហគមន៍ក្នុងតំបន់ ហើយទំនាស់នេះធ្លាយទៅដល់សាលារៀនដែលកូនចៅទៅរៀននៅក្បែរនោះថែមទៀត។

ណាន់ស៊ី ង្វៀនវ៉ែ "បូតភីកលSos" បាននិយាយថា "រឿងនេះគេហៅថា ហិង្សានៅក្នុងសាលា ពុំមែនរឿងប្រកាន់ពណ៌សម្បុរនោះទេ...វាប៉ះពាល់ដល់អ្នកទាំងអស់គ្នា...

ព្រះតេជគុណ រដ្ឋ មុន្នី ចូលរួមគាំទ្រចលនាកុមារសិស្សនៅក្រសួងអប់រំ

ដែលយើងគ្រាន់តែចង់បញ្ឈប់វាតែប៉ុណ្ណោះ..."។

លោកអាចារ្យវិហាគ្រិស្ត របីន ហែនីកា ដែលបានលើកទឹកចិត្តសិស្សឱ្យសិស្សតស៊ូប្រឆាំង "ជំងឺរ៉ាំរ៉ៃសង្គម" នោះបាននិយាយថា "អ្នកបានលើកយកបញ្ហាមកបង្ហាញជាសាធារណៈនៅពេលដែលចាស់ៗបរាជ័យរឿងនេះពីមុនមក... នៅលើផ្លូវដែលបង្កើតការផ្លាស់ប្តូរជាស្ថិយប្រវត្តក្នុងប្រវត្តអប់រំរបស់យើង"។

ថ្ងៃទី១៦ ធ្នូ សិស្សអាស៊ីសម្រេចត្រឡប់ទៅសាលាវិញ ដោយការលើកទឹកចិត្តពីក្រសួងអប់រំថា "នឹងផ្តល់ការផ្លាស់ប្តូរឱ្យសុវត្ថិភាពសាលា តែនៅតែមានអារម្មណ៍ថាផ្លូវនោះនៅឆ្ងាយ មុននឹងទៅដល់ពេលខ្លួនមានសុវត្ថិភាពពិតប្រាកដ នៅពេលទៅសាលារៀនម្តងៗ។ *(អត្ថបទដកស្រង់ពីឯកសារ ហ្វីលីពីនខម និងពីឯកសារសិស្ស)*

Continued from page 13

Plight of Sex ...

Uk Khema, the deputy chief of Tuol Sangke commune who attended the gathering, told participants in a speech that NGOs play an important role in helping sex workers get vocational training for new careers outside the sex industry.

"[NGOs] are eyes and noses for authorities, and we cannot work without participants from NGOs," Mr Khema said. "So my suggestion is that you should not concentrate on sex services, but instead work on finding vocational training for new careers to keep the value of Cambodian women," he advised the audience.

Municipal police chief Touch Naruth said on Tuesday that police have neither beaten nor arrested sex workers, and also advised that sex work was not a part of Cambodian culture.

(តមកពីទំព័រទី ១៣)

អ្នករកស៊ីផ្លូវភេទរាប់រយនាក់...

និងការរកស៊ីផ្លូវភេទពីព្រោះពួកគេបានបង្កើតឱកាសនូវការរំលោភផ្លូវភេទ និងលើរាងកាយ ដោយក្រុមមន្ត្រីអនុវត្តច្បាប់"។

លោកស្រីបាននន្ថែមថា ការចាប់ខ្លួនគួរតែត្រូវធ្វើឡើងដើម្បីជួយជនរងគ្រោះពីការជួញដូរមនុស្សពិតប្រាកដ ក៏ប៉ុន្តែថា មនុស្សពេញវ័យដែលធ្វើការដោយស្ម័ត្រចិត្តជាស្រីពេស្យាមិនគួរត្រូវចាប់ខ្លួនពីបទប្រកបការរកស៊ីរបស់ពួកគេ ជាមធ្យោបាយដើម្បីផ្តត់ផ្តង់ ជីវភាពតិចតួចសម្រាប់គ្រួសាររបស់ពួកគេឡើយ។

លោកស្រី សុខជា បានមានប្រសាសន៍ថា "ស្ត្រីខ្លះជាសរសរទ្រូងក្នុងការរកចំណូលដើម្បីចិញ្ចឹមឪពុកម្តាយ និងកូនៗរបស់ពួកគេ។

ប្រសិនបើពួកគេត្រូវចាប់ខ្លួន និងឃុំខ្លួននៅក្នុងមណ្ឌល ឬបង្ខំឱ្យទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈនរណាជាអ្នកទទួលខុសត្រូវកូនៗ និងឪពុកម្តាយដែលត្រូវដែលត្រូវការអាហារដើម្បីបរិភោគនោះ? ។

លោក អ៊ុក ខេម៉ា ជំទប់សង្កាត់ទួលសង្កែដែលចូលរួមការប្រមូលផ្តុំនេះបានប្រាប់ក្រុមអ្នកចូលរួមសន្ទរកថាមួយថា អង្គការក្រៅរដ្ឋាភិបាលដើរតួនាទីដ៏សំខាន់មួយក្នុងការជួយក្រុមអ្នករកស៊ីផ្លូវភេទទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អាជីពថ្មីក្រៅពីឧស្សាហ៍កម្មផ្លូវភេទ ។

លោក ខេម៉ា បានមានប្រសាសន៍ថា "អង្គការក្រៅរដ្ឋភិបាល គឺជាភ្នែកច្រមុះសម្រាប់អាជ្ញាធរ ហើយយើងមិនអាចធ្វើការដោយគ្មានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាលបានឡើយ" ។ លោកបានណែនាំក្រុមអ្នកចូលរួមស្តាប់ថា "ដូច្នេះសំណូមពររបស់ខ្ញុំគឺថា អ្នកមិនគួរផ្តោតលើសេវាកម្មផ្លូវភេទទេ ប៉ុន្តែគួរតែធ្វើការស្វែងរកការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អាជីពថ្មីដើម្បីរក្សាតម្លៃស្ត្រីកម្ពុជា" ។

លោក ទូច ណារ៉ុថ ស្នងការប៉ូលិសក្រុងបានមានប្រសាសន៍កាលពីថ្ងៃអង្គារ៍ថា ប៉ូលិសមិនបានវាយដំឬចាប់ខ្លួនក្រុមអ្នករកស៊ីផ្លូវភេទទេ ហើយលោកក៏បានណែនាំផងដែរថា ការរកស៊ីផ្លូវភេទមិនមែនជាផ្នែកនៃវប្បធម៌កម្ពុជាឡើយ ។

(តមកពីទំព័រទី ០៦)

ក្តីសង្ឃឹមរបស់អ្នក...

ធ្វើជាប្រធានទៀតផង ។ នេះជាការអះអាងរបស់ប្រធានសាខាបក្សវ័យក្មេង ញ៉ូយ ចំរើន ។

លោក ញ៉ូយ ចំរើន បន្ថែមទៀតថា ក្រៅពីនោះក៏នៅមានគណបក្សតូច១ចំនួនពីរផ្សេងទៀត ក៏នឹងត្រៀមខ្លួន ដើម្បីចូលរួម ជាមួយគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី តែល្អីកណា គណបក្សប្រឆាំងទាំងពីរនោះ ច្របាច់ចូលគ្នាជាគណបក្សតែមួយសិន។

ចំណែកលោក ម៉ម សូណង់ដូ នាយកវិទ្យុសំបកក្រឃ្មុំ ដែលជាប្រព័ន្ធផ្សព្វផ្សាយមានជំនោរទៅខាងអ្នកប្រជាធិបតេយ្យ ក៏នឹងត្រៀមខ្លួនចូលប្រឡូកក្នុងឆាកនយោបាយជាថ្មីម្តងទៀត ជាមួយគណបក្សសិទ្ធិមនុស្សរបស់លោក កឹម សុខា ផងដែរ ។ នេះជាការបញ្ជាក់របស់វេជ្ជបណ្ឌិត កែវ សម្បត្តិ ជាអគ្គហិរញ្ញិករបស់សាខាគណបក្សសិទ្ធិមនុស្ស ប្រចាំទ្វីបអាមេរិកខាងជើង បានឱ្យ **ខ្មែរប៉ុស្ដិ៍** ដឹងកាល ពីពេលថ្មីៗកន្លងមកនេះ ៕

សូមជួយទិញសៀវភៅខ្មែរ

អង្គការជានរណា ?

ជាស្បៀវភៅកំណត់ត្រានូវរឿងពិត ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ជំនាន់ខ្មែរក្រហមកាន់អំណាច ហើយអ្នកនិពន្ធវែកមុខអ្នកណាដែលជាឃាតករ ដែលគេឱ្យឈ្មោះថា អង្គការនោះ ។ ស្បៀវភៅរួមមានពាក្យាល :

ភ្នំពេញមុនឆ្នាំ ១៩៥៥

អ្នកនិពន្ធ កែវ ប៊ុនធឿន បានកត់ត្រាការផ្លាស់ប្តូរមុខមាត់ទីក្រុងភ្នំពេញ ពីជំនាន់មួយទៅជំនាន់មួយ និងហេតុការណ៍ដែលបានកើតឡើងក្នុងជំនាន់នោះ ។

ទាសនាខេមរៈបុត្រ :

លោក បណ្ឌិត ឌុក វ៉ាស៊ី ធ្វើអត្ថាធិប្បាយពីសិទ្ធិមនុស្ស ប្រវត្តិនៃសិទ្ធិមនុស្ស រហូតដល់យកសិទ្ធិមនុស្សធ្វើជាមូលដ្ឋាន ដើម្បីរៀបចំសង្គមរៀបចំច្បាប់រដ្ឋ ធ្វើឱ្យប្រទេសជាតិមានភាពសុខដុមរមួនា ។

បើលោកអ្នកចង់លក់ ចង់ទិញ ឬចង់ផ្សព្វផ្សាយអ្វីផ្សេងៗ សូមអញ្ជើញផ្សព្វផ្សាយក្នុងទំព័រសារព័ត៌មានខ្មែរប៉ុស្ដិ៍ ដែលអ្នកអានជាទូទៅចូលចិត្ត លោកអ្នកនឹងបានជួបភ្ញៀវរបស់លោកអ្នកយ៉ាងឆាប់រហ័ស ។

សូមទូរស័ព្ទមក **សុបិន (267) 253-3947**

ប្រវត្តិសាស្ត្រនៃកម្ពុជា

លោក វ៉ាន់ឌីកាអុន បើបនឹងសរសេរសៀវភៅប្រវត្តិសាស្ត្រនេះ ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្នកាល ។ ភាគទី១/ភាគទី២ ចេញផ្សាយរួចហើយ នៅប្រទេសបារាំង ។
Email: VANDY_KAONN@YAHOO.FR

ប្រវត្តិសាស្ត្រខ្មែរបច្ចុប្បន្ន

ថាស ស៊ីឌី ដែលរៀបរៀងដោយ ពិន សំខុន ហើយផ្សព្វផ្សាយនៅឲ្យសម្លេងខ្មែរ-អាមេរិកាំង ។ ថាស ស៊ីឌី ចំនួន បួនម៉ោងស្តីពីប្រវត្តិកម្ពុជា ចាប់តាំងពីសម្តេចនរោត្តម សីហនុ បានឡើងកាន់អំណាចនៅឆ្នាំ ១៩៤៥ មកដល់ឆ្នាំ ២00៤ ។
ទូរស័ព្ទ 215-680-2059

មានលក់នៅស្រុកអាមេរិក		ស្រុកបារាំង
-សារ៉ាម៉ានី (ខ្មែរ)	10$	10€
-រាំក្បាច់ប្រពាណ ភ្លេង ឡោន (បារាំង)	10$	10€
-រឿងភាមក្រើ (ខ្មែរ-បារាំង)	10$	10€
-ភាមក្រើតាមថែវីហារព្រះកែវមរកត (ខ្មែរ-បារាំង)	10$	10€
1-CAMBODGE (Français)	10$	10€
2-CAMBODGE (Français)	10$	10€

USA
The Khmer post
Call Sabane : (267) 253-3947

FRANCE
Cambodiana Vidéo
22.rue du Disque 75013 Paris
Tél : 01 45 84 07 57

បំណុលបញ្ជាការសែតខ្មែរប៉ុស្ដិ៍
ឈ្មោះ និងអាស័យដ្ឋានរបស់ខ្ញុំ

ឈ្មោះ :.....

អាស័យដ្ឋាន.....

ខ្ញុំចង់ជាវ :

☐ ការសែតខ្មែរប៉ុស្ដិ៍ ១ខែ មាន២លេខ ៦ខែ $30 ១២ខែ $60 ឬ 70អឺរ៉ូ សម្រាប់អឺរ៉ុប
☐ ស្បៀវភៅឈ្មោះ.....តម្លៃ $.....
☐ ស៊ីឌីប្រវត្តិសាស្ត្រខ្មែរ ៤ ម៉ោង តម្លៃមួយសិត $30
ខ្ញុំភ្ជាប់សែក ឬ មនីអង់ឌ័រ មក U.A.M.G តម្លៃ $.....
ផ្ញើមក U.A.M.G 438 LINDLEY AVE .PHILADELPHIA PA 19120
Phone : KIM PHIEN 215-680-2059 or Saben 267 253 3974

ខ្មែរប៉ុស្ដិ៍ រកអ្នកតំណាងពាណិជ្ជកម្មនៅ ឡូវែល រដ្ឋម៉ាសាឈូសែត ទទួលបានកំរៃខ្ពស់ ។
សូមទំនាក់ទំងងមក **សុបិន** តាមរយៈលេខទូរស័ព្ទ: (267) 253-3947 ។ សូមអរគុណ !

Your Advertisement Is Here For Less than $10 for two weeks!

ជំណឹងពីការលក់ និងទិញផ្ទះក្នុងតំលៃសមរម្យ
នាងខ្ញុំឈ្មោះ **សារឿន** ធ្វើការនៅការិយាល័យ Advance Realty One, LLC. " The Full Service Discount Expert," ទិញ និងលក់ផ្ទះ ។
បើអស់លោកអ្នកចង់លក់ និងទិញផ្ទះ
សូមទំនាក់ទំនងមកនាងខ្ញុំតាមលេខ :
(215) 833-6673 ។ សូមអរគុណ !

ខ្មែរប៉ុស្តិ៍
THE KHMER POST
EAST COAST
The Cambodian-American Biweekly News
Email : Khmerpostusa@gmail.com
Call : 267-254-8758

ផ្សព្វផ្សាយលេខទូរស័ព្ទ និងអាសយដ្ឋាន
លោកអ្នកក្នុងទំព័រកាសែតខ្មែរប៉ុស្តិ៍ នោះនឹង
អាចជួយពាណិជ្ជកម្មលោកអ្នកឱ្យបានច្បើនទូទ
អតិថិជនបានយ៉ាងឆាប់រហ័សឡើង ។

អានជំនាញខាងចិញ្ចឹម.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
យើងសូមតម្រង់ទិសលោកអ្នកដែលប្រើមិនិយោគ

Vinh Ho, 215-391-9516
Email: vho.realestate@consultant.com
ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148
Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!

Sav-Mor PHARMACY
Tel: 215-467-1220

ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447

បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត
▸▸Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់
ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
▸▸យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES
ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ
ឬទៅអន្តរជាតិ
*Accept most insurance plans including
Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

DRANOFF ASSOCIATES
Attorneys at Law

ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះដែលមានរបួសរូងកាយ ។
ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍៣៥ឆ្នាំ ធ្វើជាតំណាងឱ្យឯកជន ដែលពុំមែនឱ្យក្រុមហ៊ុន ឬក្រុមធានារ៉ាប់រងទេ ។
យើងធានាថា ផ្តល់គុណភាពសេវាច្បាប់យ៉ាងខ្ពស់ ហើយយកចិត្តទុកដាក់ ជាពិសេសដល់អតិថិជនរបស់យើង ។
យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យ - បានន័យថា លោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វី មុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។
ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្បានីស ខ្មែរ វៀតណាម កូរ៉េ និង ចិន ។
សូមអញ្ជើញទូរស័ព្ទមកពេលនេះភ្លាមចុះ ដើម្បីពិគ្រោះសម្ងាត់ដោយមិនគិតថ្លៃ ឬក៏អញ្ជើញមកជួបនៅការិយាល័យយើងក៏បាន ។

DRANOFF ASSOCIATES
121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

NEW PHNOM PENH RESTAURANT
○ មីបំពងគ្រឿងសមុទ្រ ○ គុយទាវគោត-គុយទាវសាច់គោ
○ ផាត់ថៃ ○ ឡុកឡាក់ ○ មាន់ឆាខ្ញី
○ បាយសាច់ជ្រូកអាំង ○ មីកន្តាំងសាច់គោ ○ បាយឆាសាច់គ្រប់មុខ

TEL.(215) 389-2122
2301 South. 7th Street. Philadelphia, PA 19148
(7th & Wolf)

Nationwide
Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់គ្មៃវជាយតម្លៃនាម

Business Liability Insurance	ធានារ៉ាប់រងជំនួញលោកអ្នក
Home Insurance	ធានារ៉ាប់រងផ្ទះសម្បែង
Health Insurance	ធានារ៉ាប់រងសុខភាព
Auto Insurance	ធានារ៉ាប់រងរថយន្ត
Life Insurance	ធានារ៉ាប់រងជីវិត

Discount 30% when you purchase
Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036

NOEL TAX CONSUL TANTS
LICENSED & INSURED
Financial Services
សេវាប្រកបដោយវិជ្ជាជីវៈ :
▸ ខ្ចីប្រាក់ទិញផ្ទះ MORTGAGE
▸ អន្តោប្រវេសន៍ IMMIGRATION
▸ បកប្រែភាសា TRANSLATION
▸ ធ្វើប្រថាប់ត្រាបញ្ជាក់លិខិតផ្លូវការ-NOTARY
▸ មានសេវាមើលកូន និងថែទាំផ្ទះសំម្បែង
ណូអែល មជ្ឈមណ្ឌលសេវាធ្វើពាក់
សម្រាប់មុខរបរ ឬឯកជន-កត់ត្រាចំណូលចំណាយប្រចាំថ្ងៃនិងប្រចាំត្រីមាស
អ្នកឯកទេសចំណាន និងធ្វើតាក់យ៉ាងប្រសើរជូនលោកអ្នក
អាស័យដ្ឋាន : 6341RISING SUN AVE
Philadelphia . PA 1911
Phone (215) 821-2443
Fax : (215) 821-2446
E-mail : noel.tax@gmail.com

ភោជនីយដ្ឋានខ្មែរ

Kavei
CAMBODIAN RESTAURANT

Authentic Khmer • Thai • Lao • Vietnamese Phở

320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)

215.952.6688

OPEN 7 DAYS A WEEK
9am-10pm

- ភោជនីយដ្ឋានយើងខ្ញុំ ចាប់ផ្តើមបើកពីថ្ងៃហើយ!
- មានម្ហូបខ្មែរពិសេសៗជាច្រើនមុខ ម្ហូបថៃ ឡាវ និង ហ្វីលីពីន
- មានទទួលសម្រាប់ពិធីជប់លាង ខួបកំណើត និង ពិធីផ្សេងៗ
- មានតន្ត្រីសម័យកំដរសៀងរាល់ល្ងាច ថ្ងៃសុក្រ-សៅរ៍-អាទិត្យ
- លោកអ្នកអាចទូរស័ព្ទមកកក់តុទុកមុនបាន
- មានកន្លែងចតរថយន្ត ដ៏ធំទូលាយ

20% OFF
DINNER
(min. order $20)
Cannot Combine with Other Offer
Expire: 12/30/09

10% OFF
DINNER TAKE OUT
(min. order $15)
Cannot Combine with Other Offer
Expire: 12/30/09